# គាំទ្រសហគ្រាសធុនតូចបំផុត ធុនតូច និងធុនមធ្យម ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា តាមរយៈការរៀបចំបន្ស៊ី គោលនយោបាយចុះបញ្ជីអាជីវកម្មឲ្យមានភាពរលូន



*Photo credit: ADB Photo | Chor Sokunthea*

DESA
Department of
Economic and
Social Affairs

# គាំទ្រសហគ្រាសធុនតូចបំផុត ធុនតូច និងធុនមធ្យម ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា តាមរយៈការរៀបចំបន្សុីគោលនយោបាយចុះបញ្ជីអាជីវកម្ម ឲ្យមានភាពរលូន

# មាតិកា


បុព្វកថារបស់នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ ........ 3

បុព្វកថារបស់ក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ........ 4

ជំពូកទី ១៖ គោលការណ៍ណែនាំសម្រាប់គោលនយោបាយសេវាក្រោមដំបូលតែមួយ (ORS) ក្នុងការចុះបញ្ជីសហគ្រាសកម្មន្តសាលធុនតូចបំផុត ធុនតូច និងមធ្យម (MSMEs) ក្នុងប្រទេសកម្ពុជា ........ 5

- I. ទិដ្ឋភាពទូទៅនៃការលូតលាស់ MSME ក្នុងប្រទេសកម្ពុជា ........ 6
- II. បញ្ហាប្រឈមដែល MSMEs ជួបប្រទះក្នុងប្រទេសកម្ពុជា ........ 7
- III. តើហេតុអ្វីបានជាការចុះបញ្ជីអាជីវកម្មនឹងអាចគាំទ្រដល់ការលូតលាស់របស់ MSMEs? ........ 8
- IV. វិសាលភាពរបស់គោលការណ៍ណែនាំ ........ 10
- V. គោលការណ៍ណែនាំសម្រាប់ការចុះបញ្ជី MSME ក្នុងវិស័យកម្មន្តសាល ........ 10
- VI. ព័ត៌មានទំនាក់ទំនងរបស់នាយកដ្ឋានរដ្ឋាភិបាលពាក់ព័ន្ធជាមួយការចុះបញ្ជី MSMEs ក្នុងប្រទេសកម្ពុជា ........ 15
- VII. ការពង្រីកគោលនយោបាយសេវាក្រោមដំបូលតែមួយដើម្បីកែលម្អក្របខ័ណ្ឌការងារនិយ័តកម្មក្នុងការចុះបញ្ជី MSME ........ 17
- VIII. លេខយោង ........ 19
- IX. ឯកសារពិគ្រោះ ........ 19

ជំពូកទី ២៖ ការអនុវត្តការចុះបញ្ជី MSME ក្នុងតំបន់អាស៊ាន៖ ករណីសិក្សាអំពីប្រទេសសិង្ហបុរី ម៉ាឡេស៊ី ថៃ និងមីយ៉ាន់ម៉ា ........ 20

- I. សេចក្តីផ្តើម ........ 21
- II. វិធីសាស្ត្រ ........ 22
- III. ការចុះបញ្ជី MSME ក្នុងប្រទេសសិង្ហបុរី ម៉ាឡេស៊ី ថៃ និងមីយ៉ាន់ម៉ា ........ 23
- IV. សន្និដ្ឋាន និងអនុសាសន៍ ........ 30

បញ្ជីឯកសារគន្ថនិទ្ទេស ........ 31

# បុព្វកថា

សហគ្រាសធុនមីក្រូ តូច និងមធ្យម(MSMEs) គឺជាសមាមាត្រដ៏ធំនៃអង្គភាពអាជីវកម្មនៅទូទាំងពិភពលោក។ ក្នុងប្រទេសកំពុងអភិវឌ្ឍ MSMEs ចូលរួមចំណែកយ៉ាងលើសលប់នៅក្នុងសកម្មភាពសេដ្ឋកិច្ច។ MSMEs គឺជាកម្លាំងដ៏ចាំបាច់សម្រាប់ការបង្កើតមុខរបរកំណើនសេដ្ឋកិច្ចការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាព។ ជាលទ្ធផលពីការចូលរួមចំណែកទាំងអស់នេះ ក៏បង្កើតឲ្យមានការឈានឡើងជាវិជ្ជមាន និងគុណភាពជីវិតកាន់តែប្រសើរមានសមធម៌កាន់តែខ្លាំងឡើងផងដែរ។

MSMEs គឺជាឆ្អឹងខ្នងសេដ្ឋកិច្ចកម្ពុជា ដោយក្នុងនោះ សហគ្រាសជាង ៩០% នៅក្នុងប្រទេសកម្ពុជាគឺជា MSMEs។ ក្នុងឆ្នាំ ២០១៨ MSMEs ផ្តល់ឱកាសការងារជាង ៧០ ភាគរយ និងជាងពាក់កណ្តាលនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។ ការកែលម្អ និងធ្វើទំនើបកម្ម MSMEs បានក្លាយជាអាទិភាពយុទ្ធសាស្ត្រមួយនៅក្នុងផែនការអភិវឌ្ឍឧស្សាហកម្ម(IDP)២០១៥-២០២៥របស់កម្ពុជា។ការផ្តួចផ្តើមគំនិតផ្នែកគោលនយោបាយជាច្រើន ត្រូវបានដាក់ចេញដើម្បីគាំទ្រដល់កំណើន MSMEs។ ការផ្តួចផ្តើមគំនិតទាំងអស់នោះ រួមមានវិធានការលើកលែងពន្ធ និងកាត់បន្ថយពន្ធ ការផ្តួចផ្តើមគំនិតបណ្តុះសហគ្រិនភាព និងយន្តការហិរញ្ញប្បទានដែលត្រូវបានតាក់តែងឡើង ដើម្បីឆ្លើយតបបញ្ហាប្រឈមដែលសហគ្រិន MSMEs ត្រូវជួបប្រទះ។

តាមរយៈគម្រោង "បើកសក្តានុពលរបស់ MSMEs ដើម្បីសម្រេចបានគោលដៅការអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ" ផ្តល់មូនិធិតាមរយៈអនុមូលនិធិរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព របស់មូលនិធិសន្តិភាព និងការអភិវឌ្ឍនៃអង្គការសហប្រជាជាតិ នៅក្នុងអង្គភាពគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនាយកដ្ឋានសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ (DSDG/DESA) មានក្តីរីករាយចូលរួមសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ (MISTI) នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងផ្តល់ជូនឯកសារបោះពុម្ពផ្សាយនេះ។ ឯកសារនេះរួមមានមគ្គុទេសក៍គោលនយោបាយ សម្រាប់ការចុះបញ្ជី MSMEs តាមបែបសាមញ្ញ និងការសិក្សាប្រៀបធៀបស្តីពីគោលនយោបាយការចុះបញ្ជី MSMEs នៅក្នុងបណ្តាប្រទេសចំនួន ៤ ក្នុងនោះរួមមានប្រទេសសិង្ហបុរី ម៉ាឡេស៊ី ថៃ និងមីយ៉ាន់ម៉ា។

របាយការណ៍នេះ ត្រូវបានបន្សីជាមួយការផ្តោតការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ក្នុងការកែលម្អបរិស្ថានគោលនយោបាយ សម្រាប់ការលូតលាស់ MSMEs ក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះ ផ្តល់ព័ត៌មានដ៏មានសារៈប្រយោជន៍ទាំងសម្រាប់អ្នកធ្វើគោលនយោបាយ និងសម្រាប់សហគ្រិន ដើម្បីរៀបចំ និងបន្សីផែនសកម្មភាពជាមួយយន្តការផ្លូវការ សម្រាប់អភិវឌ្ឍន៍ MSMEs ប្រកបដោយប្រសិទ្ធភាព។

ខ្ញុំសូមកោតសរសើរ ចំពោះកិច្ចសហប្រតិបត្តិការ ប្រកបដោយជោគជ័យ រវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ជាមួយ DSDGs/DESA និងរំពឹងថានឹងបន្តភាពជាដៃគូរបស់យើង ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍និងភាគីពាក់ព័ន្ធដ៏ទៃទៀត ដើម្បីលើកកម្ពស់សក្តានុពលរបស់ MSMEs ក្នុងការសម្រេចបាន SDGs ក្នុងប្រទេសកម្ពុជា។



Alexander Trepelkov
មន្ត្រីទទួលបន្ទុក
អង្គភាពគោលដៅអភិវឌ្ឍប្រកបដោយចីរភាព
នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ

# បុព្វកថា

ក្រោមកិច្ចដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាកន្លងមក ធ្វើឲ្យប្រទេសដែលធ្លាប់ត្រូវបានគេមើលឃើញជាប្រទេសមានសេដ្ឋកិច្ចមិនសូវលូតលាស់ លិចលង់ក្នុងភាពក្រីក្រ អាសន្ន និងសន្តិសុខស្បៀងបច្ចុប្បន្នបានក្លាយជាប្រទេសនាំចេញស្បៀងអាហារ។ កម្ពុជា គឺជាសេដ្ឋកិច្ចទើបងើបឡើងថ្មីមួយនៅក្នុងពិភពលោក ហើយបានទទួលលទ្ធផលយ៉ាងប្រសើរថ្លៃថ្លា ក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សូចនាករសង្គម ដែលថ្មីៗនេះ បានឈានចេញពីស្ថានភាពជាប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ បន្ថែមលើនេះ ប្រទេស កម្ពុជាមានក្តីប្រាថ្នាឈានទៅទទួលបានស្ថានភាពជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ ២០៥០។

សហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យម (MSMEs) ដើរតួនាទីដ៏ចាំបាច់ក្នុងប្រទេសកម្ពុជា។ សហគ្រាសទាំងនេះ បានផ្តល់ឱកាសការងារសរុបប្រមាណ ៧០% និងបានចូលរួមចំណែកចំនួន ៥៨% នៃកំណើន GDP របស់ជាតិ។ MSMEs ក៏មានសមាមាត្រប្រមាណ ៩៩,៨% នៃអង្គភាពអាជីវកម្មទាំងអស់ នៅក្នុងប្រទេសផងដែរ។ ដោយទទួលស្គាល់សារៈសំខាន់របស់ MSMEs ចំពោះសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជា បានដាក់បញ្ចូលការគាំទ្រការលូតលាស់ MSMEs ជាអាទិភាពខ្ពស់បំផុតមួយ នៅក្នុងរបៀបវារៈគោលនយោបាយរបស់ខ្លួន។ ទំនើបកម្ម MSMEs គឺជាសសរស្តម្ភយុទ្ធសាស្ត្រមួយ នៃគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជា (IDP) ២០១៥-២០២៥។ ដូចគ្នានេះដែរ MSMEs បានក្លាយជាផ្នែកកាត់ផ្តាច់ចេញមិនបានមួយ ដើម្បីបង្កើនមូលដ្ឋាននៃផលិតកម្ម និងរក្សាកំណើនសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងយុគសម័យឧស្សាហកម្ម ៤.០។ កម្រងការលើកទឹកចិត្តផ្នែកគោលនយោបាយ ត្រូវបានដាក់ឲ្យប្រើប្រាស់ដើម្បីជំរុញកំណើន MSMEs ក្នុងបំណងដើម្បីលើកកម្ពស់សហគ្រិនភាព ផ្តល់ការលើកទឹកចិត្តដល់នវានុវត្តន៍ និងពង្រីកលទ្ធភាពរបស់ MSMEs ឲ្យចូលទៅកាន់ទីផ្សារ និងទទួលបានធនធានហិរញ្ញវត្ថុ។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺជាទីភ្នាក់ងាររដ្ឋាភិបាលនាំមុខគេក្នុងប្រទេសកម្ពុជា ដែលទទួលខុសត្រូវក្នុងការគាំទ្រដល់ការលូតលាស់របស់ MSMEs។ ដោយឡែកក្រសួងនេះ ជួយសម្របសម្រួលក្នុងការបង្កើតក្របខ័ណ្ឌគោលនយោបាយស៊ីសង្វាក់គ្នា ក្នុងការលើកកម្ពស់ការចុះបញ្ជី MSMEs ជាលក្ខណៈប្រព័ន្ធ ដែលជាអាទិភាពជាយុទ្ធសាស្ត្រមួយរបស់ IDP ២០១៥-២០២៥។ ក្នុងគោលបំណងដូចបានបញ្ជាក់ខាងលើ ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម បានដាក់ឲ្យប្រើប្រាស់គោលនយោបាយសេវាក្រោមដំបូលតែមួយ (ORS) ដើម្បីធ្វើឲ្យការចុះបញ្ជី MSMEs មានលក្ខណៈជាប្រព័ន្ធ ដោយចាប់ផ្តើមចេញពីវិស័យកម្មន្តសាល។ ដោយមានគាំទ្រពីនាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (UN- DESA) ក្រសួងឧស្សាហកម្មនិងសិប្បកម្មបានអភិវឌ្ឍគោលការណ៍ណែនាំគោលនយោបាយ សម្រាប់សេវាក្រោមដំបូលតែមួយដែលនឹងអាចគាំទ្រដល់ការអនុវត្តគោលនយោបាយនៅទូទាំងប្រទេស។ គោលការណ៍ណែនាំទាំងអស់នេះ គឺជាផ្នែកដំបូងរបស់សៀវភៅណែនាំ ចំណែកនៅផ្នែកចុងក្រោយនៃសៀវភៅនេះ ក៏មានករណីសិក្សា ស្តីពីការចុះបញ្ជី MSMEs ក្នុងបណ្តាប្រទេសអាស៊ានរួមមាន ដូចជា ប្រទេសម៉ាឡេស៊ី សិង្ហបុរី ថៃ និងមីយ៉ាន់ម៉ា ដើម្បីផ្តល់ជាឯកសារពិគ្រោះដ៏មានសារៈប្រយោជន៍ ស្តីពីគោលនយោបាយចុះបញ្ជី MSMEs នៅក្នុងតំបន់។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមផ្តល់ក្តីសង្ឃឹមខ្ពស់ចំពោះកូនសៀវភៅនេះ ព្រមទាំងការចូលរួមចំណែករបស់កូនសៀវភៅទៅក្នុងការគាំទ្រដល់ការលូតលាស់ MSMEs ក្នុងប្រទេសកម្ពុជា។ តាមរយៈការបន្សុីជាមួយចក្ខុវិស័យក្នុងការស្ថាបនាសេដ្ឋកិច្ចឌីជីថល ដូចបានអនុម័តដោយនាយករដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មនិងសិប្បកម្មរំពឹងថានឹងសិក្សាស្វែងយល់លើការអនុវត្តការផ្តល់សេវាក្រោមដំបូលតែមួយ តាមបែបឌីជីថលជូនដល់សហគ្រិន MSMEs ជាពិសេស ដើម្បីលើកកម្ពស់សហគ្រិនជាស្ត្រី និងសហគ្រិនជាយុវជនក្នុងតំបន់ដាច់ស្រយាល ដែលនឹងអាចជួយបង្កើតឲ្យមានផលប៉ះពាល់ដ៏ស៊ីជម្រៅ លើការអភិវឌ្ឍសង្គមសេដ្ឋកិច្ចក្នុងប្រទេស កម្ពុជា។ យោងទៅលើផលប៉ះពាល់ជាវិជ្ជមានដ៏ធំធេង និងតួនាទីនាំមុខគេនៅក្នុងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាពក្នុងប្រទេសកម្ពុជា MSMEs និងការចូលរួមចំណែករបស់ MSMEs នៅក្នុងប្រទេស ខ្ញុំសូមអំពាវនាវឲ្យ មានការគាំទ្របន្ថែមទៀតពីសំណាក់UNDESAដៃគូអភិវឌ្ឍនិងបណ្តាប្រទេសម្ចាស់ជំនួយនានាដើម្បីលើកកម្ពស់MSMEsក្នុងការសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២០

Senior Minister
Minister of Industry & Handicraft



Kitti Setth

# ជំពូកទី ១
# គោលការណ៍ណែនាំសម្រាប់គោលនយោបាយសេវាក្រោមដំបូលតែមួយ (ORS) ក្នុងការចុះបញ្ជីសហគ្រាសកម្មន្តសាលសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ក្នុងប្រទេសកម្ពុជា

*This paper was prepared under the project supported by the 2030 Agenda for Sustainable Development Sub-Fund of the UN Peace and Development Fund (UNPDF), of which the People's Republic of China is a major contributor.*

*របាយការណ៍នេះ ត្រូវបានរៀបចំដោយវិទ្យាស្ថានទន្លេ សម្រាប់ការស្រាវជ្រាវសេដ្ឋកិច្ចប្រទេសកម្ពុជាដាក់ជូនទៅនាយកដ្ឋានសេដ្ឋកិច្ច និងកិច្ចការសង្គមសម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៃ អង្គការសហប្រជាជាតិ។ ទស្សនៈដែលបានបង្ហាញក្នុងរបាយការណ៍នេះ គឺជាទស្សនៈរបស់វិទ្យាស្ថាន និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់អង្គការសហប្រជាជាតិឡើយ។*

# I. ទិដ្ឋភាពទូទៅស្តីពីកំណើន MSME ក្នុងប្រទេសកម្ពុជា

សហគ្រាសធុនមីក្រូ តូច និងមធ្យម(MSMEs) មានសារៈសំខាន់ជាខ្លាំង សម្រាប់កំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ MSME ផ្តល់ការចូលរួមចំណែកដ៏ធំធេង ចំពោះកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព នៅទូទាំងសាកលលោក ទាក់ទងជាមួយការបង្កើតការងារសមរម្យ ការបង្កើតចំណូល និងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។ យោងតាមក្របខ័ណ្ឌការងារអភិវឌ្ឍ MSMEs កម្ពុជាឆ្នាំ ២០០៥ បញ្ជាក់ថា MSMEs ត្រូវបានកំណត់និយមន័យ ដោយចំនួននិយោជិតផង និងកម្មសិទ្ធិលើទ្រព្យសកម្មផង ដូចមានបញ្ជាក់ក្នុងតារាងទីមួយខាងក្រោម។

តារាងទី ១៖ និយមន័យ MSMEs ក្នុងប្រទេសកម្ពុជា

| | ចំនួននិយោជិត | កម្មសិទ្ធិលើទ្រព្យសកម្ម (គិតជាដុល្លារអាមេរិក) |
|---|---|---|
| ធុនតូចបំផុត | តិចជាង ១០ នាក់ | តិចជាង ៥០ ០០០ |
| ធុនតូច | ១១-៥០ នាក់ | ៥០ ០០០-២៥០ ០០០ |
| ធុនមធ្យម | ៥១-១០០ នាក់ | ២៥០ ០០០-៥០០ ០០០ |
| ធុនធំ | លើស ១០០ នាក់ | លើស ៥០០ ០០០ |

និយមន័យដូចគ្នានេះ ត្រូវបានយកមកប្រើនៅក្នុងការសិក្សាអង្កេតសេដ្ឋកិច្ចចន្លោះជំរឿនកម្ពុជាឆ្នាំ ២០១៤ (CIES, 2014)។ យោងតាមការសិក្សាអង្កេតនេះបានឲ្យដឹងថាមានគ្រឹះស្ថានសហគ្រាសចំនួន ៥១៣ ៧៥៩ ក្នុងប្រទេសកម្ពុជា។ ក្នុងនោះ ៥០១ ៦១២ គឺជាសហគ្រាសធុនតូចបំផុត ហើយ ១១ ២៥៩ គឺជាសហគ្រាសធុនតូច និងមធ្យមរួមគ្នា។ MSMEs គឺជាសមាមាត្រភាគច្រើន (៩៩,៨%) នៃចំនួនសហគ្រាសសរុបក្នុងប្រទេសកម្ពុជា។

យោងតាមរបាយការណ៍របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ក្នុងឆ្នាំ ២០១៨ MSMEs ផ្តល់ការងារជាង ៧០% និងចូលរួមចំណែកប្រមាណ ៥៨% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ប្រចាំឆ្នាំ។ ទោះយ៉ាងនេះក្តី សហគ្រាសនៅកម្ពុជា ភាគច្រើនគឺជាសហគ្រាសក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយពុំមានការចុះបញ្ជីជាផ្លូវការឡើយ។ ក្នុងចំណោមសហគ្រាសទាំងអស់ក្នុងប្រទេសកម្ពុជា មានតែសហគ្រាស ៣,៥% ប៉ុណ្ណោះដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម។ តាមការរាយការណ៍របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងឆ្នាំ ២០១៧ បានឲ្យដឹងថាមានសហគ្រាសចំនួន ១៥៨ ០០០ ក្នុងវិស័យកម្មន្តសាល។ ក្នុងនោះ សហគ្រាសចំនួន ១៥៥ ៦០០ គឺជា MSMEs ដែលផ្តល់ឱកាសការងារជាង ១លានកន្លែងក្នុងទូទាំងប្រទេស។ ការងារភាគច្រើន ក្នុងវិស័យកម្មន្តសាល គឺជាការងាររបស់ជនក្រីក្រ និងជួបការលំបាក ជាពិសេស ស្ត្រី និងយុវជនមកពីតំបន់ជនបទ។ បន្ទាប់ពី វិស័យកសិកម្ម និងសេវាកម្ម វិស័យកម្មន្តសាល គឺជាវិស័យបង្កើតការងារធំជាងគេបំផុតទីបី សម្រាប់ប្រទេសកម្ពុជា។

រូបភាពទី ១៖ មុខរបរដែលផ្តល់ដោយវិស័យឧស្សាហកម្មធំៗក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៤




*Source: World Bank Database, World Development Indicators 2019.*

## II. បញ្ហាប្រឈមដែល MSMEs ជួបប្រទះក្នុងប្រទេសកម្ពុជា

ថ្វីបើ MSME ចូលរួមចំណែកយ៉ាងធំធេងទៅក្នុងសេដ្ឋកិច្ចជាតិក្តី ប៉ុន្តែការលូតលាស់របស់ MSME នៅតែជួបប្រទះជាមួយបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងអស់នេះរួមមានដូចជាលទ្ធភាពមានកម្រិតកំណត់ ក្នុងការទទួលបានធនធានហិរញ្ញវត្ថុ និងធនធានទីផ្សារ ក្របខ័ណ្ឌការងារផ្នែកនិយ័តកម្មមិនស៊ីសង្វាក់ តំលៃវត្ថុធាតុដើមខ្ពស់ និងសមត្ថភាពសហគ្រិនភាពមានកម្រិតកំណត់។ បន្ថែមលើនេះស្ថានភាពស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់ MSMEs បានរារាំងលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានសេវាអភិវឌ្ឍអាជីវកម្ម ដែលផ្តល់ដោយរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា។

រដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ការចូលរួមវិភាគទានដ៏មានសារៈសំខាន់របស់ MSMEs ទៅក្នុងកំណើនសេដ្ឋកិច្ចជាតិ។ ការលើកកម្ពស់ និងទំនើបកម្ម MSMEs បានក្លាយជាសសរស្តម្ភមួយ ក្នុងចំណោមសសរស្តម្ភទាំងបួន នៃគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជាថ្មីៗនេះ (IDP ២០១៥-២០២៥) ដែលជាឯកសារគោលក្នុងការផ្លាស់ប្រែសេដ្ឋកិច្ចប្រទេសកម្ពុជាក្នុងលក្ខណៈជារចនាសម្ព័ន្ធ។ នៅក្នុងគោលនយោបាយអភិវឌ្ឍឧស្សាហកម្ម ២០១៥-២០២៥ គោលនយោបាយនេះ ផ្តោតគោលបំណងឲ្យ MSMEs ៨០% ទៅ ៩៥% ក្នុងប្រទេសកម្ពុជា ត្រូវបំពេញការចុះបញ្ជីផ្លូវការរបស់ខ្លួន ត្រឹមឆ្នាំ ២០២៥។

នៅក្រោមក្របខ័ណ្ឌការងារគោលនយោបាយរបស់ IDP គោលនយោបាយគាំទ្រ MSMEs ជាច្រើនត្រូវបានបានផ្តួចផ្តើម ដោយនាយកដ្ឋានផ្សេងៗរបស់រដ្ឋាភិបាល។ ក្នុងនោះរួមមានដូចជា៖

### ១. អនុក្រឹត្យ ស្តីពីការលើកលែងពន្ធលើប្រាក់ចំណេញ សម្រាប់ MSMEs ដែលចុះបញ្ជីដោយស្ម័គ្រចិត្តជាមួយអគ្គនាយកដ្ឋានពន្ធដារ (GDT) ក្នុងឆ្នាំ ២០១៧។

- ការលើកលែងពន្ធលើប្រាក់ចំណេញរយៈពេលពីរឆ្នាំ សម្រាប់ MSMEs ដែលចុះបញ្ជីដោយស្ម័គ្រចិត្តជាមួយ GDT ក្នុងឆ្នាំ២០១៧-២០១៨
- ការលើកលែងពន្ធលើប្រាក់ចំណេញរយៈពេលបីទៅប្រាំឆ្នាំសម្រាប់ MSMEs ដែលចុះបញ្ជីជាមួយ GDT ក្នុងវិស័យអាទិភាព រួមមានដូចជាវិស័យកសិកម្ម ការកែច្នៃចំណីអាហារ ទេសចរណ៍ ផលិតកម្ម នវានុវត្តន៍ និងវិស័យផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) និងការលើកលែងពន្ធត្រូវលើកលែងចំពោះ MSME ដែលត្រូវបានចុះឈ្មោះក្នុងតំបន់បន្ទុំសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSME cluster zones )។

### ២. គោលនយោបាយលើកកម្ពស់ MSME កម្ពុជា ២០១៥ ដឹកនាំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)

- ស្ថិតក្រោមការដឹកនាំក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) គោលនយោបាយលើកកម្ពស់ MSME កម្ពុជាមានបំណងឆ្លើយតបចំពោះបញ្ហាប្រឈមដែល MSME ត្រូវជួប្រទះនៅក្នុងវិស័យដូចខាងក្រោម៖

(i) បង្កើនប្រសិទ្ធផលប្រតិបត្តិការរបស់ MSME ឲ្យប្រសើរជាអតិបរមា
(ii) កែលម្អសមាហរណកម្ម MSME ទៅក្នុងទីផ្សារសាកល
(iii) ពង្រឹងសមត្ថភាពផ្នែក R&D របស់ MSME
(iv) ពង្រឹងសមត្ថភាពរបស់ MSME ឲ្យទទួលបានហិរញ្ញវត្ថុ និង
(v) លើកកម្ពស់សហគ្រិនភាពរបស់ MSME និង តួនាទីរបស់ពួកគេក្នុងនាមជាភ្នាក់ងារនវានុវត្តន៍។

បច្ចុប្បន្ន MISTI កំពុងធ្វើការលើគោលនយោបាយលើកកម្ពស់ MSME ថ្មី ២០១៩-២០២៩ ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីធនាគារអភិវឌ្ឍអាស៊ី (ADB)។ គោលបំណងសំខាន់មួយនៃគោលនយោបាយថ្មីនេះ គឺដើម្បីបង្កើនភាពស៊ីសង្វាក់នៃក្របខ័ណ្ឌការងារនិយ័តកម្ម សម្រាប់ការដាក់បញ្ចូល MSME ទៅក្នុងប្រព័ន្ធ និងទំនើបកម្ម MSME ឲ្យបានប្រសើរជាអតិបរមា។ គោលនយោបាយថ្មីនេះ នឹងត្រូវបន្សុីជាមួយអាទិភាពរបស់ផែនការអភិវឌ្ឍឧស្សាហកម្ម ២០១៥-២០២៥ និងយុទ្ធសាស្ត្រចតុកោណជាតិ សម្រាប់កំណើនសេដ្ឋកិច្ច មុខរបរ សមធម៌ និងប្រសិទ្ធផល។

គោលនយោបាយថ្មីនេះ ក៏មានបំណងដើម្បីពង្រឹងសមត្ថភាពស្ថាប័ន របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងនាមជាភ្នាក់ងារមួយដើម្បីសម្របសម្រួលក្របខ័ណ្ឌការងារនិយ័តកម្ម ក្នុងការដាក់បញ្ចូល MSME ទៅក្នុងប្រព័ន្ធរួមជាមួយអន្តរក្រសួងពាក់ព័ន្ធចំនួន ១៤ របស់រដ្ឋផងដែរ។ សម្រាប់គោលបំណងនេះ អនុគណៈកម្មាធិការទទួលបន្ទុកការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម (SCSMED) ត្រូវបានបង្កើត

ឡើង ដើម្បីសម្របសម្រួលដល់ការដាក់បញ្ចូល MSME ទៅក្នុងប្រព័ន្ធរួមជាមួយនាយកដ្ឋាននានារបស់រដ្ឋាភិបាល។ លេខាធិការដ្ឋានរបស់ SCSMED គឺស្ថិតនៅក្នុងអគ្គនាយកដ្ឋានសហគ្រាស ធុនតូច និងមធ្យម និងសិប្បកម្ម នៅក្នុងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (GDSMEH/MISTI)។ GDSMEH/MISTI ក៏ចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើតកម្មវិធីគាំទ្រ MSME ផងដែរ ដោយក្នុងនោះរួមមានដូចជា មូលនិធិអភិវឌ្ឍសហគ្រិនភាព មូលនិធិពង្រឹងជំនាញ ក៏ដូចជាការបង្កើតធនាគារ MSME កម្ពុជាផងដែរ។

## ៣. គោលនយោបាយសេវាក្រោមដំបូលតែមួយ (ORS) សម្រាប់ការចុះបញ្ជី MSME យ៉ាងស៊ីសង្វាក់

ចាប់ពីឆ្នាំ ២០១៨ មក ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចាប់ផ្តើមដាក់ឲ្យអនុវត្តគោលនយោបាយសេវាក្រោមដំបូលតែមួយ (ORS) ដើម្បីលើកកម្ពស់ភាពស៊ីសង្វាក់នៃការចុះបញ្ជី MSME។ គោលនយោបាយ ORS មានបំណងផ្តល់សេវាសំចតតែមួយកន្លែង សម្រាប់សហគ្រិន MSME ក្នុងការចុះបញ្ជីអាជីវកម្មរបស់ខ្លួន និងដើម្បីលើកកម្ពស់ប្រសិទ្ធផល និងតម្លាភាពនៅក្នុងបរិស្ថាននៃការធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជា។ ដោយធ្វើការរួមគ្នាជាមួយអន្តរក្រសួងពាក់ព័ន្ធចំនួន ១៨ ពាក់ព័ន្ធជាមួយការចុះបញ្ជី MSME GDSMEH នឹងសម្របសម្រួលការអនុវត្តគោលនយោបាយ ORS ព្រមទាំងលើកកម្ពស់ការផ្តល់សេវាតាមឌីជីថលរបស់ខ្លួន ជូនដល់សហគ្រិន MSME ទូទាំងប្រទេស។ សម្រាប់គោលបំណងនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខិតខំខ្នះខ្នែងដើម្បីពង្រឹងកិច្ចសហការជាមួយអន្តរក្រសួងពាក់ព័ន្ធចុះឲ្យរដ្ឋាភិបាលសំខាន់ៗ ដែលធ្វើការពាក់ព័ន្ធជាមួយការចុះបញ្ជី MSME។ អន្តរក្រសួងពាក់ព័ន្ធទាំងនោះរួមមានដូចជា អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (GDT) ក្រសួងពាណិជ្ជកម្ម (MoC) និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MLVT)។ វិស័យកម្មន្តសាលដែលក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវមើលខុសត្រូវដោយផ្ទាល់ ត្រូវបានផ្តល់អាទិភាពឲ្យជាវិស័យអនុវត្តសាកល្បងដើម្បីអនុវត្តគោលនយោបាយ (ORS)។

## ៤. មជ្ឈមណ្ឌលផ្តួចផ្តើមអាជីវកម្មបច្ចេកវិទ្យា ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)

ក្នុងកិច្ចឆ្លើយតបជាមួយចក្ខុវិស័យ ដើម្បីសម្រេចបានឧស្សាហកម្ម ៤.0 និងសេដ្ឋកិច្ចឌីជីថលក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី (Techno Startup Center) ត្រូវបានសម្ពោធឲ្យប្រើប្រាស់ក្នុងខែមេសា ឆ្នាំ ២០១៩ រួមគ្នាដោយឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា (MoEYS)។ មជ្ឈមណ្ឌលនេះមានទីតាំងក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញនេះ មានបំណងក្លាយជាមជ្ឈមណ្ឌលឧត្តមភាពដែលគាំទ្រការលូតលាស់ប្រកបដោយជោគជ័យរបស់អ្នកចាប់ផ្តើមធ្វើអាជីវកម្មដឹកនាំដោយយុវជនតាមរយៈការពង្រឹងសហគ្រិនភាព និងសមត្ថភាពនវានុវត្តន៍ ជាពិសេសនៅក្នុងវិស័យនវានុវត្តន៍ និងបច្ចេកវិទ្យា។ មជ្ឈមណ្ឌលផ្តល់ការបណ្តុះបណ្តាល និងសេវាគ្រូបង្វឹក ដើម្បីប្រែក្លាយគំនិតនវានុវត្តន៍របស់សហគ្រិនវ័យក្មេងទៅជាគំរូអាជីវកម្ម ដែលត្រូវបានពិចារណាគ្រប់ជ្រុងជ្រោយ។ តាមរយៈការអនុវត្តអភិក្រមប្រព័ន្ធអេកូឡូស៊ី មជ្ឈមណ្ឌលនេះដើរតួនាទីជាតំណភ្ជាប់រវាងសហគ្រិនវ័យក្មេង ជាមួយបណ្តាញអ្នកវិនិយោគមូលនិធិសម្រាប់ផ្តួចផ្តើមអាជីវកម្ម និងមន្ទីរពិសោធន៍ស្រាវជ្រាវ ដែលអាចជួយបំពាក់នវានុវត្តន៍របស់យុវជនឲ្យមានលក្ខណៈទំនើបបំផុត។ មជ្ឈមណ្ឌលនេះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមូលនិធិលើកកម្ពស់សហគ្រិនភាព (EPF)។ EPF ដែលមានថវិកាប្រចាំឆ្នាំចំនួន ៥ លានដុល្លារ គឺជាមូលនិធិមួយគ្រប់គ្រងដោយ MEF មានបំណងផ្តល់ការគាំទ្រដល់ MSMEs និងការផ្តួចផ្តើមអាជីវកម្មក្នុងប្រទេសកម្ពុជា នៅដំណាក់កាលផ្តួចផ្តើមដំបូងរបស់ខ្លួន មជ្ឈមណ្ឌលនេះ បើកទ្វារជូនចំពោះអ្នកទើបបញ្ចប់ការសិក្សាវ័យក្មេងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានអប់រំនៅមុខដទៃទៀតក្នុងរាជធានីភ្នំពេញ។ មជ្ឈមណ្ឌលនេះ នឹងអាចផ្តល់សេវាកាន់តែច្រើនថែមទៀត ជូនដល់សហគ្រិនវ័យក្មេង ប្រសិនបើវិសាលភាពសេវារបស់ខ្លួនអាចពង្រីកទៅដល់យុវជនមកពីសហគមន៍ជនបទតាមបណ្តាខេត្តនានា។

# III. ហេតុអ្វីបានជាការចុះបញ្ជីអាជីវកម្ម នឹងអាចគាំទ្រដល់ការលូតលាស់ MSMEs?

MSMEs ភាគច្រើនក្នុងប្រទេសកម្ពុជា គឺជាអង្គភាពអាជីវកម្មក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ លក្ខណៈក្រៅប្រព័ន្ធនេះ ក៏ធ្វើឲ្យមានបញ្ហាប្រឈមជាច្រើនសម្រាប់ការលូតលាស់របស់ MSMEs ផងដែរ ហើយក្នុងនោះមានបញ្ហាប្រឈមបីដែលធ្ងន់ធ្ងរជាងគេបំផុត។ បញ្ហាប្រឈមទីមួយ គឺកង្វះលទ្ធភាពទទួលបានហិរញ្ញប្បទាន។ ក្នុងប្រទេសកម្ពុជា គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការផ្តល់កម្ចីជាចម្បងទៅឲ្យអង្គភាពអាជីវកម្មដែលបានចុះបញ្ជី។ ក្នុងករណីជាច្រើន ការចុះបញ្ជីអាជីវកម្មផ្លូវការ គឺជាបុរេលក្ខខណ្ឌដើម្បីអាចបើកគណនីធនាគារ និងដាក់ពាក្យសុំកម្ចី។ បន្ថែមលើនេះ MSME ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាពិសេស គឺសហគ្រាសទើបចាប់ផ្តើមដំបូង និងសហគ្រាសធុនមីក្រូ ជារឿយៗតែងខ្វះសមត្ថភាព ដើម្បីរក្សាការកត់ត្រាបញ្ជី និងកំណត់ត្រាហិរញ្ញវត្ថុបានច្បាស់លាស់ ដែលហេតុធ្វើឲ្យបាត់បង់ទំនុកចិត្តលើម្ចាស់សហគ្រាសចំពោះមុខគ្រឹះស្ថានហិរញ្ញវត្ថុនៅចំពោះមុខស្ថាប័នហិរញ្ញវត្ថុ។

ពេលប្រឈមមុខជាមួយបញ្ហាប្រឈមនេះជារឿយៗ MSMEs ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចាំបាច់ត្រូវស្វែងរកប្រភពហិរញ្ញវត្ថុជាជម្រើសជំនួសផ្សេងវិញរួមមានដូចជាប្រាក់សន្សំផ្ទាល់ខ្លួន ខ្ចីពីគ្រួសារ ការផ្ញើរប្រាក់ពីក្រៅប្រទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣៦ ដែលបានចុះបញ្ជីក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៦ (NBC, 2016)។ ប៉ុន្តែ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនបានចុះបញ្ជីផងទៃទៀតជាច្រើន ដែលភាគច្រើនប្រមូលផ្តុំនៅក្រុងភ្នំពេញ និងតំបន់សេដ្ឋកិច្ចនានា ដូចជាខេត្តសៀមរាបជាដើម។ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតិចតួចប៉ុណ្ណោះដែលមានវត្តមានក្នុងតំបន់ដទៃ ជាហេតុធ្វើឲ្យលទ្ធភាពរបស់ MSMEs ក្នុងការទទួលបានធនធានហិរញ្ញវត្ថុកាន់តែមានកម្រិតកំណត់ថែមទៀត។

បញ្ហាប្រឈមទីពីរ គឺកង្វះលទ្ធភាពចូលទៅកាន់ទីផ្សារ។ ប្រសិនបើគ្មានការចុះបញ្ជីផ្លូវការទេ MSMEs អាចមានការលំបាកជាខ្លាំងក្នុងការចូលទៅកាន់ទីផ្សារអន្តរជាតិ យោងតាមសិក្សាអង្កេតមួយ ធ្វើឡើងដោយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) ក្នុងឆ្នាំ ២០១៨ បានបង្ហាញថា MSMEs បានចូលរួមចំណែកតិចជាង ១០% ទៅក្នុងការនាំចេញរបស់ប្រទេស បើទោះបីជា MSMEs មានសមមាត្រលើសពី ៩០% នៃអង្គភាពអាជីវកម្មទាំងអស់ក្តី។ រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំខ្នះខ្នែង ដើម្បីលើកកម្ពស់ការនាំចេញរបស់ប្រទេសកម្ពុជា។ ទោះយ៉ាងនេះក្តី នៅពុំទាន់មានគោលនយោបាយលើកកម្ពស់ការនាំចេញសម្រាប់ MSMEs នៅឡើយ។ ស្ថានភាពស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់ MSME បានរាំងមិនឲ្យស្ថាប័នរដ្ឋនានារបស់រដ្ឋាភិបាលអាចយល់ច្បាស់អំពីតម្រូវការរបស់សហគ្រិន MSME និងផ្តល់គោលនយោបាយដើម្បីគាំទ្រការនាំចេញរបស់ MSME នៅក្នុងលក្ខណៈបែបជំរុញតម្រូវការបានទេ។

បញ្ហាប្រឈមទីបីគឺសហគ្រិន MSME មានលទ្ធភាពក្នុងកម្រិតកំណត់ ដើម្បីទទួលបានសេវាការគាំទ្រការអភិវឌ្ឍអាជីវកម្ម។ ឧទាហរណ៍ មូលនិធិអភិវឌ្ឍសហគ្រិន (EDF) ដែលទើបត្រូវបានដាក់ឲ្យប្រើប្រាស់នាពេលថ្មីៗនេះ និងមូលនិធិអភិវឌ្ឍជំនាញ (SDF) គឺបើកឲ្យជាចម្បងសម្រាប់តែ MSMEs ដែលបានចុះបញ្ជីប៉ុណ្ណោះ។ ជាការលំបាកសម្រាប់ស្ថាប័នរដ្ឋនានារបស់រាជរដ្ឋាភិបាល ក្នុងការយល់ឲ្យបានពេញលេញអំពីតម្រូវការរបស់ MSMEs នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងអាចផ្តល់កម្មវិធីដែលសមស្របទៅតាមតម្រូវការទាំងនោះ។ ស្របពេលជាមួយគ្នានេះដែរ សហគ្រិន MSME ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក៏មានការយល់ដឹងកម្រិតកំណត់អំពីលក្ខណៈសម្បត្តិរបស់ខ្លួន ដើម្បីអាចចូលទៅក្នុងកម្មវិធីអភិវឌ្ឍអាជីវកម្មផងដែរ។ ថ្វីបើមានកម្មវិធីគាំទ្រការអភិវឌ្ឍអាជីវកម្ម ផ្តល់ដោយរដ្ឋាភិបាល និងអង្គការនានាក្តី ប៉ុន្តែកម្មវិធីទាំងនោះភាគច្រើន គឺប្រមូលផ្តុំនៅតំបន់រាជធានីភ្នំពេញ។ មាន MSMEs ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងតំបន់ជនបទតែមួយចំនួនតូចប៉ុណ្ណោះ ដែលអាចមានលទ្ធភាពទទួលបានសេវាគាំទ្រការអភិវឌ្ឍអាជីវកម្ម ជាហេតុធ្វើឲ្យរាំងដល់ការលូតលាស់សហគ្រិនភាព។

ដោយមានទស្សនៈដូចខាងលើ ការចុះបញ្ជីអាជីវកម្មនឹងអាចនាំយកអត្ថប្រយោជន៍ដូចខាងក្រោម ជូនដល់ MSMEs ក្នុងនោះមានជាអាទិ៍៖

- ការពង្រីកលទ្ធភាពទទួលបានហិរញ្ញវត្ថុ៖ ក្នុងនាមជាអាជីវកម្មដែលបានចុះបញ្ជី MSMEs នឹងមានសមត្ថភាពអាចបើកគណនីធនាគារ លើកកម្ពស់ភាពគួរជាទីទុកចិត្ត និងពង្រឹងលទ្ធភាពទទួលបានហិរញ្ញវត្ថុពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។
- ការពង្រីកលទ្ធភាពចូលទៅកាន់ទីផ្សារ៖ ការចុះបញ្ជីអាជីវកម្មនឹងអាចគាំទ្រដល់ MSMEs ឲ្យទទួលបានលិខិតអនុញ្ញាតសម្រាប់ការនាំចេញ និងអាជ្ញាប័ណ្ណដែលចាំបាច់ សម្រាប់សមាហរណកម្មពួកគេចូលទៅក្នុងសង្វាក់តម្លៃសាកល។
- ការពង្រីកលទ្ធភាពចូលទៅកាន់កម្មវិធីសេវាអភិវឌ្ឍអាជីវកម្ម៖ ការចុះបញ្ជីអាជីវកម្មនឹងអាចជួយផ្តល់ព័ត៌មានអំពីតម្រូវការ និងបញ្ហាប្រឈមដែល MSMEs ត្រូវជួបប្រទះ ដើម្បីតាក់តែង និងផ្តល់កម្មវិធីការគាំទ្រការអភិវឌ្ឍអាជីវកម្មដឹកនាំដោយស្ថាប័នរដ្ឋនានារបស់រាជរដ្ឋាភិបាលនិង អង្គការអន្តរជាតិនានា។

ថ្វីបើមានអត្ថប្រយោជន៍ជាច្រើនក្តី ប៉ុន្តែ MSMEs ក្នុងចំនួនដ៏ច្រើននៅប្រទេសកម្ពុជា នៅតែងចង់បន្តស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការសិក្សាអង្កេតនាពេលថ្មីៗនេះមួយ ធ្វើឡើងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងឆ្នាំ ២០១៩ បានរាយការណ៍ថា ជាងពាក់កណ្តាលនៃសហគ្រិន MSME ដែលបានសម្ភាសន៍បានបង្ហាញភាពស្ទាក់ស្ទើរ មិនចង់ចុះបញ្ជីអាជីវកម្មរបស់ខ្លួនជាផ្លូវការឡើយ។

មូលហេតុចម្បងមួយដែលបានរកឃើញ គឺដោយសារការចំណាយខ្ពស់ និងត្រូវអស់ពេលច្រើន ដើម្បីចុះបញ្ជី។ យោងតាមសន្ទស្សន៍គោលនយោបាយ MSME អាស៊ាន ២០១៨ ដើម្បីចុះបញ្ជីអាជីវកម្មមួយក្នុងប្រទេសកម្ពុជា គឺត្រូវការពេលជាមធ្យម ៩៩ ថ្ងៃ ហើយទាមទារអាជ្ញាប័ណ្ណប្រមាណ ៧៥ ពីស្ថាប័នរដ្ឋនានារបស់រាជរដ្ឋាភិបាល។ បន្ថែមលើនេះ នៅពុំទាន់មានគោលការណ៍ណែនាំ ដែលផ្តល់កម្រងព័ត៌មានទាំងស្រុងស្តីពីឯកសារ និងជំហានដែលចាំបាច់ត្រូវធ្វើ ដើម្បីទទួលបានអាជ្ញាប័ណ្ណឡើយ។ មូលហេតុមួយទៀត ដែលសហគ្រិន MSME នៅតែបន្តស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺការភ័យខ្លាចបាត់បង់ភាពប្រកួតប្រជែង តាមរយៈការចុះបញ្ជីដែលអាចធ្វើឲ្យការចំណាយប្រតិបត្តិការ អាជីវកម្ម កាន់តែខ្ពស់រួមទាំងការបង់ពន្ធ និងថ្លៃសេវាផ្សេងៗ បើប្រៀបជាមួយអ្នកដែលពុំបានចុះបញ្ជី។

ដើម្បីគាំទ្រដល់ការលូតលាស់របស់ MSMEs តាមរយៈការចុះបញ្ជីផ្លូវការ របាយការណ៍នេះ ផ្តល់គោលការណ៍ណែនាំ ស្តីពីឯកសារ និងជំហាននានាដែលចាំបាច់ សម្រាប់ការចុះបញ្ជីអាជីវកម្មនៅក្នុងវិស័យកម្មន្តសាល។ របាយការណ៍ពន្យល់អំពីបរិបទផ្នែកស្ថាប័ន នៃការចុះបញ្ជីអាជីវកម្មក្នុងប្រទេសកម្ពុជា។ របាយការណ៍ក៏ស្វែងយល់អំពីវិធីនានា ដើម្បីកែលម្អបរិស្ថាននិយ័តកម្ម នៃការចុះបញ្ជីអាជីវកម្មក្នុងប្រទេសកម្ពុជាផងដែរ។

## IV. វិសាលភាពគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះមានបំណងផ្តល់សារពើភ័ណ្ឌឯកសារ និងជំហានដែលចាំបាច់ដើម្បីចុះបញ្ជីក្នុងវិស័យកម្មន្តសាលក្នុងប្រទេសកម្ពុជា។ វិស័យកម្មន្តសាលក្នុងគោលការណ៍ណែនាំនេះ រួមមានដូចជា ១) ផលិតកម្មអាហារ ភេសជ្ជៈ និងថ្នាំជក់ ២) ផលិតកម្មវាយនភណ្ឌ កាត់ដេរ និងស្បែក ៣) ផលិតផលកែច្នៃក្រដាស ៤) ផលិតកម្មផលិតផលគីមី កៅស៊ូ និងប្លាស្ទិច ៥) ផលិតផលប្រភេទរ៉ែមិនមែនលោហៈ ៦) ផលិតកម្មលោហៈកម្រិតមូលដ្ឋាន ៧) កែច្នៃលោហៈ និងគ្រឿងចក្រ ៨) ឧបករណ៍កម្មន្តសាល និងគ្រឿងបរិក្ខារការិយាល័យ។ គោលការណ៍ណែនាំនេះមិនត្រូវយកទៅអនុវត្តចំពោះការចុះបញ្ជី MSME ក្នុងវិស័យសំណង់ សេវា និងពាណិជ្ជកម្មទេ។

## V. គោលការណ៍ណែនាំសម្រាប់ការចុះបញ្ជី MSME ក្នុងវិស័យកម្មន្តសាល

ផ្នែកនេះផ្តល់មគ្គុទេសក៍សម្រាប់សហគ្រិន MSME ក្នុងវិស័យកម្មន្តសាល សម្រាប់ការចុះបញ្ជីអាជីវកម្មរបស់ខ្លួន។ ផ្នែកនេះបញ្ជាក់អំពីឯកសារ និងជំហានដែលជាការតម្រូវដោយស្ថាប័នរដ្ឋនានារបស់រាជរដ្ឋាភិបាលចំនួនបួន ពាក់ព័ន្ធជាមួយការចុះបញ្ជី MSME ផ្នែកកម្មន្តសាល រួមមានក្រសួងពាណិជ្ជកម្ម (MoC) អគ្គនាយកដ្ឋានពន្ធដារ (GDT) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)។ យោងតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាមួយការចុះបញ្ជីអាជីវកម្មក្នុងវិស័យកម្មន្តសាល ការចុះបញ្ជីអាជីវកម្ម អាចត្រូវបានបំពេញចប់សព្វគ្រប់ តែនៅក្រោយពេលចុះបញ្ជីប្រកបដោយជោគជ័យជាមួយស្ថាប័នទាំងបួននេះប៉ុណ្ណោះ។ សូមបញ្ជាក់ថា ឯកសារ ជំហាន និងថ្លៃសេវាដែលជាការតម្រូវពីនាយកដ្ឋានរដ្ឋាភិបាល សម្រាប់ការចុះបញ្ជី MSME ដែលមានរៀបរាប់នៅក្នុងផ្នែកនេះ គឺអាចមានការកែសម្រួលទៅតាមការកែតម្រូវបច្ចុប្បន្នភាព ពីសំណាក់នាយកដ្ឋានរដ្ឋាភិបាល។ សហគ្រិន MSME ត្រូវបានលើកទឹកចិត្តឲ្យទំនាក់ទំនងទៅជនបង្គោលរដ្ឋាភិបាលទទួលបន្ទុកការចុះបញ្ជីអាជីវកម្ម ដើម្បីកំណត់រកព័ត៌មានថ្មីៗបំផុត។ បញ្ជីព័ត៌មានទំនាក់ទំនងជនបង្គោល គឺមានផ្តល់ជូនក្នុងផ្នែកទីប្រាំមួយ នៃរបាយការណ៍នេះ។

### ១. ឯកសារ និងជំហានជាការតម្រូវសម្រាប់ការចុះបញ្ជី MSME នៅក្រសួងពាណិជ្ជកម្ម (MoC)

ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងការចុះបញ្ជីតម្រូវឲ្យMSMEs ចាំបាច់ត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដើម្បីទទួលបានវិញ្ញាបនបត្រសារជីវកម្ម។ ការតម្រូវនេះ ត្រូវអនុវត្តទាំងចំពោះ MSMEs ជាកម្មសិទ្ធិរបស់ពលរដ្ឋកម្ពុជា ក៏ដូចជាសាខាសហគ្រាសពហុជាតិ (MNEs) ដែលធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជា។ ចាំបាច់ត្រូវមានជំហានចំនួនបីដើម្បីបំពេញការចុះបញ្ជីអាជីវកម្ម និងទទួលបានវិញ្ញាបនបត្រសារជីវកម្ម ពីក្រសួងពាណិជ្ជកម្ម។

រូបភាពទី ២៖ ជំហានទាំងបីសម្រាប់ការចុះបញ្ជីអាជីវកម្មនៅក្រសួងពាណិជ្ជកម្ម

| | |
|---|---|
| ជំហានទី ១ | បង្កើតគណនីចុះបញ្ជីតាមអនឡាញ និងដាក់បង្ហោះព័ត៌មានទូទៅ ស្តីពីសហគ្រាស |
| ជំហានទី ២ | ដាក់ឯកសារតាមការតម្រូវជូនទៅក្រសួងពាណិជ្ជកម្ម ឬសាខាតាមខេត្តរបស់ក្រសួង |
| ជំហានទី ៣ | ទទួលវិញ្ញាបនបត្រសារជីវកម្ម |

ក្នុងជំហានទីមួយ សហគ្រិន MSME ចាំបាច់ត្រូវចាប់ផ្តើមដោយការដាក់ពាក្យតាមអនឡាញ នៅគេហទំព័រចុះបញ្ជីអាជីវកម្ម www.businessregistration.moc.gov.kh របស់ក្រសួងពាណិជ្ជកម្ម។ សហគ្រិន ចាំបាច់ត្រូវបង្កើតគណនីមួយនៅលើគេហទំព័រនេះ។ សហគ្រិនត្រូវបង្ហោះឯកសារដូចជា អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់ខ្លួន ដើម្បីធ្វើឲ្យគណនីតាមអនឡាញនេះមានសកម្មភាព។ បន្ទាប់ពីបង្កើតគណនីរួចហើយ សហគ្រិនចាំបាច់ត្រូវផ្តល់ព័ត៌មានបន្ថែម តាមរយៈគណនីរបស់ខ្លួន ដោយក្នុងនោះរួមមាន៖

១. ភាពជាម្ចាស់កម្មសិទ្ធិលើសហគ្រាស (ឧ. ថាតើសហគ្រាសនេះ គឺជាសហគ្រាសសហកម្មសិទ្ធិ ឬជាសហគ្រាសឯកបុគ្គល)
២. ស្នើឈ្មោះ និងរក្សាទុកឈ្មោះរបស់សហគ្រាស
៣. ការពិពណ៌នាទូទៅអំពីសកម្មភាពអាជីវកម្ម
៤. អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងរបស់ម្ចាស់
៥. ចំនួននិយោជិក

សហគ្រិននឹងបានទទួលអ៊ីម៉ែលឆ្លើយតបបញ្ជាក់ ដើម្បីជម្រាបប្រាប់ថាគណនីរបស់ខ្លួន ត្រូវបានចុះបញ្ជីដោយជោគជ័យ ហើយព័ត៌មានត្រូវបានបង្ហោះរួចហើយ។ ថ្លៃសេវានឹងត្រូវគិតតាមអនឡាញ ដើម្បីរក្សាឈ្មោះសហគ្រាស។ នៅពេលការបង់ប្រាក់តាមអនឡាញ ត្រូវបានបញ្ចប់ដោយជោគជ័យហើយ ឈ្មោះអាជីវកម្មនោះអាចត្រូវបានរក្សាទុកសម្រាប់សហគ្រាសជាអ្នកដាក់ពាក្យរយៈពេល ៣០ ថ្ងៃ។

សម្រាប់ជំហានទីពីរ ក្នុងរយៈ ១៥ ថ្ងៃ បន្ទាប់ពី គណនីចុះបញ្ជីតាមអនឡាញត្រូវបានបង្កើត ហើយ សហគ្រិនចាំបាច់ត្រូវទំនាក់ទំនងទៅក្រសួងពាណិជ្ជកម្ម ឬសាខាតាមខេត្តរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីដាក់ឯកសារដូចខាងក្រោម៖

១. ឯកសារដែលមានបញ្ជាក់ឈ្មោះ អាសយដ្ឋាន ព័ត៌មានទំនាក់ទំនង និងប្រភេទកម្មសិទ្ធិលើសហគ្រាស
២. សំណៅច្បាប់ដើមនៃកិច្ចព្រមព្រៀងស្តីពី រចនាសម្ព័ន្ធការកាន់ភាគហ៊ុនក្រុមហ៊ុន
៣. រូបថត អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ អ្នកកាន់ភាគហ៊ុន និងសមាជិកក្រុមប្រឹក្សាភិបាល
៤. លិខិតមានចុះហត្ថលេខាដោយម្ចាស់សហគ្រាស ជាការប្រកាសថាខ្លួនមិនធ្លាប់មានកំណត់ត្រាព្រហ្មទណ្ឌនៅក្នុងសំណុំរឿងពាណិជ្ជកម្ម ស៊ីវិល ឬព្រហ្មទណ្ឌណាមួយឡើយ។ លិខិតនេះ ក៏គួរប្រកាសថាម្ចាស់សហគ្រាសបច្ចុប្បន្ន ពុំមែនជាមន្ត្រីរដ្ឋាភិបាលដែលត្រូវចងកាតព្វកិច្ចដោយសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជានោះដែរ
៥. សំណៅច្បាប់ដើមចំនួនពីរច្បាប់នៃលក្ខន្តិកៈសហគ្រាស រួមជាមួយរបាយការណ៍បញ្ជាក់ប្រាក់បញ្ញើនៅធនាគារ។

សហគ្រិន ក៏ចាំបាច់ត្រូវជម្រាបប្រាប់ក្រសួងពាណិជ្ជកម្ម អំពីលេខគណនីដែលខ្លួនបានទទួលពីគេហទំព័រចុះបញ្ជីសាជីវកម្មរបស់ក្រសួងពាណិជ្ជកម្មផងដែរ។

សម្រាប់ជំហានទីបី សហគ្រិននឹងទទួលបានវិញ្ញាបនបត្រសាជីវកម្មពីក្រសួងពាណិជ្ជកម្ម ប្រសិនបើឯកសារដែលបានដាក់ជូនគ្រប់គ្រាន់នឹងពេញលេញទៅតាមការពិនិត្យការពិនិត្យឡើងវិញរបស់ក្រសួងពាណិជ្ជកម្ម។ ទោះយ៉ាងនេះក្តី ពេលវេលាដែលក្រសួងពាណិជ្ជកម្ម ត្រូវការដើម្បីពិនិត្យឡើងវិញលើឯកសារទាំងនោះ គឺនៅពុំទាន់បានបញ្ជាក់ច្បាស់នៅឡើយ។

## ២. ឯកសារ និងជំហានដែលជាការតម្រូវសម្រាប់ការចុះបញ្ជី MSME នៅអគ្គនាយកដ្ឋានពន្ធដារ (GDT)

ការចុះបញ្ជី MSME ជាមួយ GDT គឺជាការតម្រូវស្តីពី ច្បាប់ពន្ធដារ ដើម្បីបានទទួលវិញ្ញាបនបត្រពន្ធចាំបាច់ សម្រាប់អង្គភាពអាជីវកម្មដើម្បីបង់ពន្ធប្រភេទជាកាតព្វកិច្ចលើពន្ធតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ និងពន្ធប្រភេទដទៃទៀតដែលជាការតម្រូវរបស់រដ្ឋាភិបាល។ មានបីជំហានដែលចាំបាច់ត្រូវបំពេញការចុះបញ្ជីនៅ GDT។

### រូបភាពទី ៣៖ ជំហានទាំងបីសម្រាប់ការចុះបញ្ជីអាជីវកម្ម នៅអគ្គនាយកដ្ឋានពន្ធដារ

| | |
|---|---|
| ជំហានទី ១ | បោះត្រាវិញ្ញាបនបត្រសាជីវកម្មនៅ GDT |
| ជំហានទី ២ | ដាក់ឯកសារតាមការតម្រូវជូនដល់ការិយាល័យ GDT |
| ជំហានទី ៣ | ទទួលវិញ្ញាបនបត្រពន្ធ |

ក្នុងជំហានទីមួយ សហគ្រិន MSME ចាំបាច់ត្រូវយកវិញ្ញាបនបត្រសាជីវកម្មដែលបានទទួលពីក្រសួងពាណិជ្ជកម្មយកទៅបោះត្រានៅអគ្គនាយកដ្ឋានពន្ធដារ។ សហគ្រិនក៏ចាំបាច់ត្រូវទៅការិយាល័យ GDT ផ្ទាល់ផងដែរ ព្រោះត្រូវផ្តិតមេដៃ និងថតរូប។

ជំហានទីពីរ សហគ្រិនចាំបាច់ត្រូវបំពេញទម្រង់លើក្រដាស ដែលត្រូវដាក់ជូនទៅការិយាល័យ GDT រួមជាមួយឯកសារដូចខាងក្រោម៖
១. វិញ្ញាបនបត្រសារជីវកម្មបានទទួលពីក្រសួងពាណិជ្ជកម្ម
២. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនមានសុពលភាព និងរូបថតថ្មីៗរបស់សហគ្រិនចំនួនពីរសន្លឹក
៣. វិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធិ ឬកិច្ចព្រមព្រៀងជួលមានសុពលភាព សម្រាប់កន្លែងធ្វើការរបស់សហគ្រាស
៤. វិក័យបត្របញ្ជាក់ការទទួលពន្ធលើចលនទ្រព្យ
៥. ព័ត៌មានអំពីគណនីធនាគាររបស់សហគ្រាស

ក្នុងជំហានទីបី បន្ទាប់ពីបានដាក់ឯកសារដូចខាងលើហើយ ម្ចាស់ MSME ចាំបាច់ត្រូវបង់ថ្លៃដាក់ពាក្យនៅការិយាល័យ GDT។ តម្លៃដែលត្រូវបង់គឺ ៥ដុល្លារ សម្រាប់សហគ្រាសដែលត្រូវបាន GDT ចាត់ចំណាត់ថ្នាក់សហគ្រាសធុនតូច (មានកម្រៃសរុបប្រចាំឆ្នាំចន្លោះពី ៦២ ៥០០ដុល្លារ ដល់ ១៧៥ ០០០ដុល្លារ ) និងត្រូវបង់ ១០០ដុល្លារ សម្រាប់សហគ្រាសធុនមធ្យម (ប្រាក់កម្រៃសរុបប្រចាំឆ្នាំចន្លោះ ១៧៥ ០០០ដុល្លារ ដល់ ១ លានដុល្លារ)។ សហគ្រិនត្រូវបានរំពឹងថា នឹងទទួលវិញ្ញាបនបត្រពន្ធក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់ពី GDT បានទទួលការដាក់ពាក្យ។

### ៣. ឯកសារ និងជំហានដែលចាំបាច់សម្រាប់ចុះបញ្ជី MSME នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT)

ការចុះបញ្ជី MSME ជាមួយ MLVT គឺជាការតម្រូវតាមច្បាប់ ស្តីពីការងារដើម្បីបានទទួលលេខសម្គាល់អត្តសញ្ញាណសហគ្រាស នៅក្រោមបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ដែលអាចយកទៅប្រើប្រាស់ ដើម្បីតាមដានលើការបង់ភាគទានរបស់សហគ្រាស ចូលមកក្នុងសន្តិសុខសង្គមរបស់និយោជិតរបស់ខ្លួន។ ជាទូទៅ គឺការចុះបញ្ជីនេះមានបីជំហាន។

រូបភាពទី ៤៖ ជំហានទាំងបីសម្រាប់ការចុះបញ្ជីអាជីវកម្មនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)

| | |
|---|---|
| ជំហានទី ១ | បំពេញទម្រង់ដាក់ពាក្យលេខ ១.០១ និងដាក់ឯកសារតាមការតម្រូវ |
| ជំហានទី ២ | បំពេញទម្រង់ដាក់ពាក្យលេខ ១.០២ និងដាក់ព័ត៌មានអំពីនិយោជិត |
| ជំហានទី ៣ | ទទួលបានលេខអត្តសញ្ញាណសហគ្រាសនៅក្រោម ប.ស.ស |

ក្នុងជំហានទីមួយ សហគ្រិន MSME ចាំបាច់ត្រូវទៅការិយាល័យ MLVT ដោយផ្ទាល់ ហើយបំពេញទម្រង់ពាក្យសុំលេខ ១.០១ ដើម្បីបានទទួលលេខអត្តសញ្ញាណសហគ្រាស។ MLVT មិនផ្តល់សេវាតាមអនឡាញដូចក្រសួងពាណិជ្ជកម្មទេ។ ទម្រង់ ១.០១ អាចយកពីការិយាល័យរបស់ MLVT។ ម្យ៉ាងទៀតទម្រង់នេះ ក៏មាននៅក្នុងឯកសារភ្ជាប់របស់ប្រកាស (សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីជាភាសាខ្មែរ) លេខ ៤៤៨ ស្តីពីការចុះបញ្ជីសហគ្រាស និងនិយោជិតនៅប.ស.សដែលចេញដោយ MLVT។ បន្ថែមលើទម្រង់ដាក់ពាក្យ សហគ្រិនក៏ចាំបាច់ផ្តល់ឯកសារដូចខាងក្រោម៖
១. វិញ្ញាបនបត្រសាជីវកម្មបានទទួលពីក្រសួងពាណិជ្ជកម្ម
២. វិញ្ញាបនបត្រពន្ធបានទទួលពី GDT
៣. បញ្ជីរាយឈ្មោះនិយោជិត
៤. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់សហគ្រិន

ក្នុងជំហានទីពីរ សហគ្រិនចាំបាច់ត្រូវចុះបញ្ជីនិយោជិតទាំងអស់ នៅក្នុងសហគ្រាសជាមួយ MLVT ដែលទាមទារឲ្យមានការបំពេញទម្រង់ដាក់ពាក្យលេខ ១.០២។ ទម្រង់នេះ អាចយកបានពីការិយាល័យ MLVT។ ម្យ៉ាងទៀត ទម្រង់នេះក៏មាននៅក្នុងឯកសារភ្ជាប់របស់ប្រកាសលេខ ៤៤៨ ស្តីពីការចុះបញ្ជីសហគ្រាស និងនិយោជិតនៅបេឡាជាតិសន្តិសុខសង្គម (NSSF) ផងដែរ។ សហគ្រិនចាំបាច់ត្រូវដាក់អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់និយោជិត ជាឯកសារភ្ជាប់ដើម្បីបំពេញទម្រង់ ១.០២។

សម្រាប់ជំហានទីបី លេខអត្តសញ្ញាណសហគ្រាសសម្រាប់ប.ស.ស នឹងត្រូវផ្តល់ជូនដល់ សហគ្រិន បន្ទាប់ពីបានបញ្ចប់ពីរជំហានខាងដើមដោយជោគជ័យ។ ពេលវេលាដែលត្រូវការ ដើម្បីឲ្យ MLVT ផ្តល់លេខអត្តសញ្ញាណដល់សហគ្រាស គឺនៅពុំទាន់បានបញ្ជាក់នៅឡើយ។

## ៤. ការចុះបញ្ជីនៅក្រសួងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(MISTI)

បន្ថែមលើ ការចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ MSMEs ផ្នែកកម្មន្តសាលក៏ត្រូវបានតម្រូវដោយរដ្ឋាភិបាលកម្ពុជា ឲ្យចុះបញ្ជីជាមួយក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ផងដែរ ដើម្បីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការសហគ្រាស។ ការចុះបញ្ជីនេះ គឺជាការតម្រូវដោយច្បាប់ស្តីពី រដ្ឋបាលរោងចក្រ និងសិប្បកម្ម។ មានឯកសារ និងជំហានផ្សេងគ្នាដែលត្រូវយកមកអនុវត្ត ចំពោះសហគ្រាសដែលមាន ឬសហគ្រាសដែលមិនមានការតម្រូវឲ្យទទួលបានការអនុញ្ញាតសម្រាប់ការបង្កើត។ ដោយហេតុនេះមុនពេលចុះបញ្ជីជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សហគ្រិន MSME ត្រូវបានលើកទឹកចិត្តឲ្យពិនិត្យមើលប្រកាសលេខ ១៩៨ ចេញដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងឆ្នាំ ២០១៦ ហើយកំណត់ថាតើការចុះបញ្ជីរបស់ខ្លួន នឹងត្រូវស្នើឲ្យដាក់ពាក្យសុំការអនុញ្ញាតការបង្កើត ឬទេ។ ជាទូទៅមានជំហានចំនួនបួនដែលចាំបាច់ សម្រាប់ក្នុងការទទួលបានលិខិតអនុញ្ញាតគ្រឹះស្ថាន សហគ្រាស ហើយត្រូវការពីរជំហានសម្រាប់អ្នកដែលមិនមានការតម្រូវនេះ។

### ១) សហគ្រាសដែលទាមទារការអនុញ្ញាតគ្រឹះស្ថាន

MSMEs ផ្នែកកម្មន្តសាលទាំងអស់ ដែលតម្រូវឲ្យមានការអនុញ្ញាតគ្រឹះស្ថាន ត្រូវអនុវត្តតាមជំហានទាំងបួនដូចខាងក្រោម ដើម្បីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

រូបភាពទី ៥ ៖ ជំហានទាំងបួនសម្រាប់ការចុះបញ្ជីអាជីវកម្មនៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)សម្រាប់ MSMEs ដែលទាមទារលិខិតអនុញ្ញាតគ្រឹះស្ថាន

| | |
|---|---|
| ជំហានទី ១ | ដាក់ពាក្យសុំលិខិតអនុញ្ញាតគ្រឹះស្ថាន និងដាក់ពាក្យសុំឯកសារដែលជាការតម្រូវ |
| ជំហានទី ២ | ទទួលបានការអនុញ្ញាតគ្រឹះស្ថាន |
| ជំហានទី ៣ | ដាក់ពាក្យសុំអាជ្ញាប័ណ្ណប្រតិបត្តិការ និងដាក់ពាក្យសុំដាក់ឯកសារតាមការតម្រូវ |
| ជំហានទី ៤ | ទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការ |

ក្នុងជំហានទីមួយ សហគ្រិន MSME ចាំបាច់ត្រូវទៅការិយាល័យ MLVT ដោយផ្ទាល់ ហើយបំពេញទម្រង់ពាក្យសុំលេខ ១.០១ ដើម្បីបានទទួលលេខអត្តសញ្ញាណសហគ្រាស។ MLVT មិនផ្តល់សេវាតាមអនឡាញដូចក្រសួងពាណិជ្ជកម្មទេ។ ទម្រង់ ១.០១ អាចយកពីការិយាល័យរបស់ MLVT។ ម្យ៉ាងទៀតទម្រង់នេះ ក៏មាននៅក្នុងឯកសារភ្ជាប់របស់ប្រកាស (សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីជាភាសាខ្មែរ) លេខ ៤៤៨ ស្តីពីការចុះបញ្ជីសហគ្រាស និងនិយោជិតនៅប.ស.សដែលចេញដោយ MLVT។ បន្ថែមលើទម្រង់ដាក់ពាក្យ សហគ្រិនក៏ចាំបាច់ផ្តល់ឯកសារដូចខាងក្រោម៖

១. វិញ្ញាបនបត្រសាជីវកម្មបានទទួលពីក្រសួងពាណិជ្ជកម្ម
២. វិញ្ញាបនបត្រពន្ធបានទទួលពី GDT
៣. បញ្ជីរាយឈ្មោះនិយោជិត
៤. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់សហគ្រិន

ក្នុងជំហានទីពីរ សហគ្រិនចាំបាច់ត្រូវចុះបញ្ជីនិយោជិតទាំងអស់ នៅក្នុងសហគ្រាសជាមួយ MLVT ដែលទាមទារឲ្យមានការបំពេញទម្រង់ដាក់ពាក្យលេខ ១.០២។ ទម្រង់នេះ អាចយកបានពីការិយាល័យ MLVT។ ម្យ៉ាងទៀត ទម្រង់នេះក៏មាននៅក្នុងឯកសារភ្ជាប់របស់ប្រកាសលេខ ៤៤៨ ស្តីពីការចុះបញ្ជីសហគ្រាស និងនិយោជិតនៅបេឡាជាតិសន្តិសុខសង្គម (NSSF) ផងដែរ។ សហគ្រិនចាំបាច់ត្រូវដាក់អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់និយោជិត ជាឯកសារភ្ជាប់ដើម្បីបំពេញទម្រង់ ១.០២។

ជំហានទី ៣ ៖ ដាក់ពាក្យស្នើសុំប្រកាសបង្កើតរោងចក្រ-សហគ្រាស។ បន្ទាប់ពីបានទទួលលិខិតអនុញ្ញាតគ្រឹះស្ថានហើយ សហគ្រិន MSME ផ្នែកកម្មន្តសាលក៏ចាំបាច់ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណប្រតិបត្តិការពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ឯកសារដែលត្រូវការសម្រាប់ការដាក់ពាក្យសុំរួមមាន៖

១. ទម្រង់ដាក់ពាក្យសុំអាជ្ញាប័ណ្ណប្រតិបត្តិការដែលបានបំពេញរួចពេញលេញ

២. រូបថតរបស់ម្ចាស់ MSME

៣. លិខិតអនុញ្ញាតគ្រឹះស្ថានដែលបានអនុម័តរួច

៤. របាយការណ៍វាយតម្លៃ ពីមន្ត្រីបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្តីពីលក្ខខណ្ឌផលិតកម្មរបស់សហគ្រាស

៥. លិខិតតំណាងដោយអាណត្តិ ប្រសិនបើមាន

៦. រូបថត ឈ្មោះសហគ្រាស និងប្លង់លំហូរប្រតិបត្តិការរបស់រោងចក្រ-សិប្បកម្ម

៧. ឯកសារដទៃទៀត ដែលត្រូវការដូចជាវិញ្ញាបនបត្រពាក់ព័ន្ធជាមួយគុណភាពផលិតផលភស្តុតាងបញ្ជាក់ការចុះបញ្ជីម៉ាកយីហោ និងលិខិតអនុម័តលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន។

ថ្លៃសេវាសម្រាប់ការដាក់ពាក្យសុំនៅ MISTI គឺ ១៨,៧៥ដុល្លារ សម្រាប់សហគ្រាសធុនតូចបំផុត ៣៧ដុល្លារ សម្រាប់សហគ្រាសធុនមីក្រូ និង ៧៥ដុល្លារ សម្រាប់សហគ្រាសធុនមធ្យម។

នៅពេលបានទទួលការដាក់ពាក្យពេញលេញហើយ MISTI នឹងបញ្ជូនមន្ត្រីទៅវាយតម្លៃអគារ សហគ្រាស រោងជាង និងបរិក្ខារប្រតិបត្តិការក្នុងរយៈពេលប្រាំថ្ងៃធ្វើការអនុលោមតាមផែនការនៃការរចនា និងប្លង់លំហូរការងារដែលមាននៅក្នុងប្រកាសបង្កើតរោងចក្រ-សិប្បកម្ម។

ជំហានទី ៤ ៖ បានទទួលអាជ្ញាប័ណ្ណប្រតិបត្តិការ។ ប្រសិនបើ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រកឃើញថាសហគ្រាសមានភាពអនុលោមតាមលិខិតអនុញ្ញាតគ្រឹះស្ថានពេញលេញនោះវិញ្ញាបនបត្រអនុញ្ញាតដំណើការរោងចក-សិប្បកម្មត្រូវប្រគល់ជូនក្នុងរយៈពេល ១៥ថ្ងៃធ្វើការងារបន្ទាប់ពី MISTI បានទទួលការដាក់ពាក្យពេញលេញ។

## ២) សហគ្រាសដែលមិនទាមទារការអនុញ្ញាតគ្រឹះស្ថាន

សហគ្រាសដែលមិនទាមទារឲ្យមានលិខិតអនុញ្ញាតគ្រឹះស្ថានអាចដាក់ពាក្យដោយផ្ទាល់ដើម្បីសុំអាជ្ញាប័ណ្ណប្រតិបត្តិការ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

### រូបភាពទី ៦ ៖ ជំហានទាំងពីរ សម្រាប់ការចុះបញ្ជីអាជីវកម្មនៅ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(MISTI) សម្រាប់ MSMEs ដែលពុំត្រូវការលិខិតអនុញ្ញាតគ្រឹះស្ថាន

| | |
|---|---|
| ជំហានទី ១ | ដាក់ពាក្យដោយផ្ទាល់ដើម្បីសុំអាជ្ញាប័ណ្ណប្រតិបត្តិការ និងដាក់ឯកសារតាមការតម្រូវ |
| ជំហានទី ២ | ទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការ |

សម្រាប់ជំហានទីមួយ សហគ្រិនចាំបាច់ត្រូវដាក់ពាក្យសុំជូនទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឬការិយាល័យតាមខេត្តរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលជាទីតាំងរបស់សហគ្រាស។ ឯកសារចាំបាច់មាន៖

១. ទម្រង់ពាក្យសុំអាជ្ញាប័ណ្ណប្រតិបត្តិការដែលបានបំពេញរួច

២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថតបីសន្លឹករបស់សហគ្រិន MSME

សម្រាប់ជំហានទីពីរ សហគ្រិន MSME នឹងបានទទួលអាជ្ញាប័ណ្ណប្រតិបត្តិការរបស់ខ្លួន ក្នុងរយៈពេលប្រាំពីរថ្ងៃធ្វើការ ប្រសិនបើការដាក់ពាក្យនោះ ត្រូវបានបំពេញដោយជោគជ័យ ហើយការវាយតម្លៃរបស់ MISTI រកឃើញថា លក្ខខណ្ឌប្រតិបត្តិការមានលក្ខណៈស៊ីគ្នាជាមួយលក្ខខណ្ឌការរចនាលំហូរនៃសហគ្រាស។

## VI. ព័ត៌មានទំនាក់ទំនងជាមួយស្ថាប័នរដ្ឋពាក់ព័ន្ធនានាជាមួយការចុះបញ្ជី MSME ក្នុងប្រទេសកម្ពុជា

ផ្នែកខាងលើបានបង្ហាញ កម្រងឯកសារ និងជំហាននានាទាំងស្រុង ដែលជាការតម្រូវសម្រាប់ការចុះបញ្ជី MSME ក្នុងវិស័យកម្មន្តសាល។ ដើម្បីបានទទួលព័ត៌មានបន្ថែម ស្តីពីការចុះបញ្ជី MSME របស់នាយកដ្ឋានទៅទៀតទទួលបន្ទុកវិស័យឧស្សាហកម្ម ដូចជាសំណង់ ពាណិជ្ជកម្ម និង សេវាជាដើមសហគ្រិនគួរពិនិត្យព័ត៌មានទំនាក់ទំនង របស់នាយកដ្ឋានពាក់ព័ន្ធរបស់រដ្ឋាភិបាល ដូចខាងក្រោម។ ផ្នែកខាងលើបានបង្ហាញ កម្រងឯកសារ និងជំហាននានាទាំងស្រុង ដែលជាការតម្រូវសម្រាប់ការចុះបញ្ជី MSME ក្នុងវិស័យកម្មន្តសាល។ ដើម្បីបានទទួលព័ត៌មានបន្ថែម ស្តីពីការចុះបញ្ជី MSME របស់នាយកដ្ឋានទៅទៀតទទួលបន្ទុកវិស័យឧស្សាហកម្ម ដូចជាសំណង់ ពាណិជ្ជកម្ម និង សេវាជាដើម សហគ្រិនគួរពិនិត្យព័ត៌មានទំនាក់ទំនង របស់នាយកដ្ឋានពាក់ព័ន្ធរបស់រដ្ឋាភិបាល ដូចខាងក្រោម។

| ក្រសួង/ស្ថាប័ន | ព័ត៌មានទំនាក់ទំនង |
|---|---|
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) អគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | ទូរសព្ទលេខ៖ (៨៥៥) ២៣ ២២ ៣៨ ០២<br>អ៊ីមែល៖ gdsmeh@gmail.com<br>គេហទំព័រ៖ www.mih.gov.kh |
| ក្រសួងពាណិជ្ជកម្ម (MoC) នាយកដ្ឋានចុះបញ្ជីអាជីវកម្ម | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៨៦៦ ០៥០/ ២៣ ៨៦៦ ៤៥៩<br>អ៊ីមែល៖ moc.gov.kh@gmail.com<br>គេហទំព័រ៖ www.moc.gov.kh |
| ក្រសួងទេសចរណ៍ (MoT) នាយកដ្ឋានគ្រប់គ្រងសេវាកន្លែងស្នាក់នៅ និងចំណីអាហារ | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៥៣១០៩៩៩<br>អ៊ីមែល៖ camaccommodationdept@gmail.com<br>គេហទំព័រ៖ www.tourismcambodia.org |
| ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (MAFF) អគ្គនាយកដ្ឋានកសិកម្ម | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៧២៦ ១២៨ / ២៣ ៧២៦ ១២៩<br>អ៊ីមែល៖ info@maff.gov.kh \| គេហទំព័រ៖ www.maff.gov.kh |
| អគ្គនាយកដ្ឋានពន្ធដា (GDT) | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៨៨៦ ៧០៨<br>អ៊ីមែល៖ gdt@tax.gov.kh \| គេហទំព័រ៖ www.tax.gov.kh |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៤៣០ ២២៥<br>អ៊ីមែល៖ info_gdfi@mef.kh \| គេហទំព័រ៖ www.gdfi.mef.gov.kh |
| ក្រសួងសុខាភិបាល (MoH) អគ្គនាយកដ្ឋានសុខាភិបាល | ទូរសព្ទលេខ៖ (៨៥៥-២៣) ៨៨៥-៩៧០/៨៨៤ ៩០៩<br>អ៊ីមែល៖ webmaster@moh.gov.kh \| គេហទំព័រ៖ www.moh.gov.kh |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT)អគ្គនាយកដ្ឋានមុខរបរ | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៨៨ ៤៣ ៧៥<br>អ៊ីមែល៖ N/A \| គេហទំព័រ៖ www.mlvt.gov.kh |
| ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) អគ្គនាយកដ្ឋានសំណង់ | ទូរសព្ទលេខ៖ (៨៥៥) ២៣ ២១៥ ៦៦០ / ២១៥ ៦៥៩<br>អ៊ីមែល៖ gdadmin-mlmupc@camnet.com.kh<br>គេហទំព័រ៖ www.mlmupc.gov.kh |
| ក្រសួងបរិស្ថាន (MoE) អគ្គនាយកដ្ឋានការពារបរិស្ថាន | ទូរសព្ទលេខ៖ (៨៥៥) ២៣ ២១៣ ៩០៨/ ២៣ ២២០ ៣៦៩<br>អ៊ីមែល៖ info@moe.gov.kh \| គេហទំព័រ៖ www.moe.gov.kh |

| ក្រសួង/ស្ថាប័ន | ព័ត៌មានទំនាក់ទំនង |
|---|---|
| ក្រសួងរ៉ែ និងថាមពល (MME) អគ្គនាយកដ្ឋាន (ធនធានរ៉ែ/ ថាមពល/ ឥន្ធនៈ) អាស្រ័យលើសកម្មភាពអាជីវកម្មដែលពាក់ព័ន្ធជាមួយនាយកដ្ឋានខាងលើ។ | ទូរសព្ទលេខ៖ (៨៥៥) ២ ៨៩០ ៣៣០<br>អ៊ីមែល៖ info@mme.gov.kh \| គេហទំព័រ៖ www.mme.gov.kh |
| បេឡាជាតិរបបសន្តិសុខសង្គម (NSSF) | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៨៨២ ៤៣៤/ ២៣ ៨៨២ ៦២៣<br>អ៊ីមែល៖ គ្មាន \| គេហទំព័រ៖ www.nssf.gov.kh |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៤២៦ ៥១០/ ២៣ ៧២៤ ៨០៩<br>អ៊ីមែល៖ info@mptc.gov.kh \| គេហទំព័រ៖ www.mptc.gov.kh |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | ទូរសព្ទលេខ៖ (៨៥៥) ៨៨/ ១៥/៦៧ ៩២៩ ០៩០<br>អ៊ីមែល៖ info@mpwt.gov.kh \| គេហទំព័រ៖ www.mpwt.gov.kh<br>ការចុះបញ្ជីអាជ្ញាប័ណ្ណផ្នែកដឹកជញ្ជូន៖<br>www.transportlicense.mpwt.gov.kh |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ | ទូរសព្ទលេខ៖ (៨៥៥) ២៣ ២១៨ ១៤៨<br>អ៊ីមែល៖ info@mcfa.gov.kh \| គេហទំព័រ៖ www.mcfa.gov.kh |
| ក្រសួងអប់រំ | ទូរសព្ទលេខ៖ (៨៥៥) ២៣២១៩ ២៨៥<br>អ៊ីមែល៖ info@moeys.gov.kh \| គេហទំព័រ៖ www.moeys.gov.kh |
| ក្រសួងព័ត៌មាន | ទូរសព្ទលេខ៖ (៨៥៥) ១២ ៦៧៤ ៥៦៧/ ៩៧ ៧៨៨ ៣៣៣៣<br>អ៊ីមែល៖ kheangveng@gmail.com \|<br>គេហទំព័រ៖ www.information.gov.kh |
| ក្រសួងមហាផ្ទៃ | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៧២១ ៩០៥<br>អ៊ីមែល៖ info@interior.gov.kh \| គេហទំព័រ៖ www.interior.gov.kh |
| ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា | ទូរសព្ទលេខ៖ (៨៥៥) ២៣ ៩៨១ ១៥៤/ ២៣ ៩៨១ ១៦៧<br>អ៊ីមែល៖ kanelleheang@yahoo.com<br>គេហទំព័រ៖ www.cdc-crdb.gov.kh |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | ទូរសព្ទលេខ៖ (៨៥៥) ២៣ ២១ ៤០ ៦៥<br>អ៊ីមែល៖ info-pru@customs.gov.kh<br>គេហទំព័រ៖ www.customs.gov.kh |

# VI. ការពង្រីកគោលនយោបាយក្រោមដំបូលតែមួយដើម្បីកែលម្អក្របខណ្ឌការងារ និយ័តកម្មការចុះបញ្ជី MSME

ដូចបានបញ្ជាក់ខាងលើហើយថា នៅក្នុងក្របខណ្ឌការងារនិយ័តកម្មអាជីវកម្មបច្ចុប្បន្នក្នុងប្រទេសកម្ពុជា សហគ្រាសទាំងអស់ត្រូវបានតម្រូវឲ្យចុះបញ្ជីជាមួយក្រសួងនានាជាជំហានដំបូងបំផុត ដោយក្នុងនោះមានក្រសួងពាណិជ្ជកម្ម (MoC) អគ្គនាយកដ្ឋានពន្ធដា (GDT) និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT)។ការចុះបញ្ជីជាមួយនាយកដ្ឋានទាំងបីរបស់រដ្ឋាភិបាលអាចផ្តល់វិញ្ញាបនបត្រសាជីវកម្មជូនដល់សហគ្រាសដែលចេញដោយក្រសួងពាណិជ្ជកម្ម វិញ្ញាបនបត្រពន្ធចេញដោយអគ្គនាយកដ្ឋានពន្ធដារ និងលេខអត្តសញ្ញាណសហគ្រាសចេញដោយ ប.ស.ស របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាអាជ្ញាប័ណ្ណចាំបាច់ទាំងបីសម្រាប់ប្រតិបត្តិការអាជីវកម្មផ្លូវការ។ បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណទាំងបី សហគ្រាសចាំបាច់ទៅត្រូវដាក់ពាក្យ សុំអាជ្ញាប័ណ្ណប្រតិបត្តិការបន្ថែម ពីនាយកដ្ឋានរដ្ឋាភិបាលដទៃទៀត ទទួលបន្ទុកវិស័យឧស្សាហកម្មដែលសហគ្រាសនោះកំពុងប្រតិបត្តិការ។ឧទាហរណ៍ក្នុងវិស័យកម្មន្តសាលសហគ្រាសចាំបាច់ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណប្រតិបត្តិការពីឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)។ ក្រសួងតាមវិស័យតម្រូវឲ្យសហគ្រាសត្រូវផ្តល់ឯកសារបន្ថែមដើម្បីបានទទួលអាជ្ញាប័ណ្ណ ដែលខ្លួនចេញឲ្យ។ មានការប៉ាន់ប្រមាណថា មានអាជ្ញាប័ណ្ណប្រមាណ ៧៥ អាជ្ញាប័ណ្ណ ដែលចាំបាច់ត្រូវមានដើម្បីបំពេញការចុះបញ្ជីអាជីវកម្ម ក្នុងប្រទេសកម្ពុជា ( ASEAN SME Policy Index, 2018 )។

រូបភាពទី ៧ ៖ ទិដ្ឋភាពផ្នែកស្ថាប័នសម្រាប់ការចុះបញ្ជីសហគ្រាស់ក្នុងប្រទេសកម្ពុជា




ដោយមិនមានការចង្អុលបង្ហាញច្បាស់លាស់ស្តីពីឯកសារ និងជំហានដែលចាំបាច់ សហគ្រិន MSME អាចមានការភ័ន្តភាំងយ៉ាងងាយស្រួលក្នុងដំណើរការចុះបញ្ជីដែលមានលក្ខណៈរប៉ាត់រប៉ាយ និងស្ថិតក្រោមការដឹកនាំដាច់ៗពីគ្នាពីសំណាក់នាយកដ្ឋានផ្សេងៗរបស់រដ្ឋាភិបាល។ ទិដ្ឋភាពនេះជួយពន្យល់អំពីការចំណាយពេលវេលា និងប្រាក់កាសដែលធ្វើឲ្យសហគ្រិន MSME មានភាពស្ទាក់ស្ទើរក្នុងការចុះបញ្ជី និងធ្វើឲ្យអាជីវកម្មរបស់ខ្លួនមានលក្ខណៈផ្លូវការ។

ដើម្បីគាំទ្រដល់ការលូតលាស់ MSME និងកែលម្អការចុះបញ្ជី MSME ក្នុងលក្ខណៈស៊ីសង្វាក់គ្នា រដ្ឋាភិបាលកម្ពុជាបានដាក់ឲ្យប្រើក្របខណ្ឌការងារអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម (SMEs) ក្នុងឆ្នាំ ២០០៤ ដែលបានក្លាយជាក្របខណ្ឌការងារគោលនយោបាយគ្រឹះសម្រាប់គោលនយោបាយគាំទ្រ MSME នាពេលក្រោយៗមកទៀត រួមទាំងគោលនយោបាយអភិវឌ្ឍ MSME ឆ្នាំ ២០១៩-២០២៩ ដែលត្រូវបានអភិវឌ្ឍឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ក្នុងឆ្នាំ ២០០៤ អនុគណកម្មាធិការអភិវឌ្ឍ SME ( SCSMED ) ក៏ត្រូវបានបង្កើតឡើង ដែលមានអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និង សិប្បកម្ម ( GDSMEH/MISTI ) ជាប្រធាន។ SCSMED គឺជាស្ថាប័នសម្របសម្រួលអន្តរនាយកដ្ឋានទទួលបន្ទុកធ្វើផែនការ អនុវត្ត និងធ្វើការ

វាយតម្លៃផលប៉ះពាល់លើគោលនយោបាយគាំទ្រ MSME ក្នុងប្រទេសកម្ពុជា។ SCSMED រួមមានសមាសភាពអ្នកតំណាងមកពីស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាលរួមទាំងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងទេសចរណ៍ ក្រសួងរ៉ែ និងថាមពល ក្រសួងអភិវឌ្ឍជនបទ ក្រសួងបរិស្ថាន និងក្រសួងកិច្ចការនារីអគ្គនាយកដ្ឋានពន្ធដារ និងធនាគារជាតិនៃកម្ពុជា។

តាំងពីបានចាប់បដិសន្ធិមក SCSMED បានព្យាយាមកែលម្អភាពស៊ីសង្វាក់នៃបរិស្ថាននិយ័តកម្មដើម្បីធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជា។ ដោយឈរលើមូលដ្ឋាននៃ GDSMEH/MISTI ថ្មីៗនេះ SCSMED បានដាក់ឲ្យប្រើគោលនយោបាយសេវាក្រោមដំបូលតែមួយ (ORS) សម្រាប់ការចុះបញ្ជីអាជីវកម្ម។ ការបង្កើត ORS មានបំណងធ្វើឲ្យដំណើរការចុះបញ្ជី MSME មានលក្ខណៈជាប្រព័ន្ធដោយបច្ចុប្បន្ន ដំណើរការនេះនឹងមានភាពមិនស៊ីសង្វាក់គ្នាទៅតាមក្រសួងផ្សេងៗជាច្រើន។ម្យ៉ាងទៀត គោលនយោបាយនេះក៏នឹងផ្តល់សេវាសំចតតែមួយសម្រាប់សហគ្រិន MSME ដើម្បីបានទទួលព័ត៌មានបច្ចុប្បន្នភាពស្តីពីវិធាន និងនិយ័តកម្មនានាទាក់ទងជាមួយការចុះបញ្ជី MSME។ ការិយាល័យ ORS ត្រូវបានបង្កើតឡើងនៅក្នុង MISTI ដើម្បីសម្របសម្រួលការអនុវត្តគោលនយោបាយ។ ORS តំណាងឲ្យនិន្នាការជាយុទ្ធសាស្ត្រដើម្បីកែលម្អ បរិយាកាសគោលនយោបាយសម្រាប់ធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជា ដែលអាចចូលរួមចំណែកឈានទៅសម្រេចបានគោលដៅយុទ្ធសាស្ត្ររបស់ផែនការអភិវឌ្ឍឧស្សាហកម្ម ២០១៥-២០២៥ ក្នុងការធ្វើឲ្យ MSMEs ៨០-៩៥ ភាគរយ ប្រែមកស្ថិតនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ វិធានការគោលនយោបាយបំពេញបន្ថែម គួរតែមានសារៈប្រយោជន៍ដើម្បីលើកកម្ពស់ការចូលរួមចំណែករបស់ ORS ទៅក្នុងការដាក់ឲ្យ MSME ចូលមកក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធរួមទាំងការវិភាគផលប៉ះពាល់ពេញលេញ និង ការ ស្ថាបនាវេទិកាតាមអនឡាញ ដែលពង្រីកលទ្ធភាពរបស់សហគ្រិន MSME តាមទីជនបទឲ្យអាចទទួលបានសេវា ORS។ ការគាំទ្រការអភិវឌ្ឍអាជីវកម្មក៏អាចត្រូវបានដាក់បញ្ចូលរួមជាមួយ ORS ដើម្បីលើកទឹកចិត្តដល់ការចុះបញ្ជីសម្រាប់សហគ្រិន MSME ផងដែរ។

# លេខយោង


i. Cambodia's Small Businesses Serve as Backbone of Sustainable Economy (2013) https://asiafoundation.org/2013/05/15/cambodias-small-businesses-serve-as-backbone-of-sustainable-economy.

ii. CDC. SME development framework (2005-2010). http://www.cdc-crdb.gov.kh/cdc/7cg_meeting/7cg_document/draft_outline_sme.htm and MIH and JICA (2014). SME Promotion Survey.

iii. Baily, P.(2008). Cambodia small and medium enterprise sized enterprises: constraints, policies and proposals for their development, In Lim H.(ed), SME in Asia and Globalization, ERIA Research Report 2007-5,pp.1-36.


# ឯកសារពិគ្រោះ


1. ASEAN 2018 SME Policy Index Boosting Competitiveness and Inclusive Growth (2018)
2. Baily, P(2008).Cambodia small and medium enterprise sized enterprises: constraints, policies and proposals for their development, In Lim H.(ed), SME in Asia and Globalization, ERIA Research Report 2007-5,pp.1-36.
3. ច្បាប់ស្ដីពីការងារនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៧)
4. ការអង្កេតចន្លោះជំរឿនសេដ្ឋកិច្ចនៅកម្ពុជា ២០១៤ ការវិភាគលទ្ធផលអង្កេត (២០១៥)
5. គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (២០១៥-២០២៥)
6. CDC. ក្របខ័ណ្ឌអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម (២០០៥-២០១០) http://www.cdc-crdb.gov.kh/cdc/7cg_meeting/7cg_document/draft_outline_sme.htm
7. Hutt, D. (2017), "Cambodia's microfinance industry: Why bigger may not be better", The Diplomat, https://thediplomat.com/2017/08/cambodias-microfinance-industry-why-biggermay-not-be-better/ .
8. ប្រកាសរួមស្ដីពី "ការផ្ដល់សេវាសាធារណៈ និងពិន័យអន្តរការណ៍ជាប្រាក់" (២០១៥) រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
9. ច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម (២០០៦)
10. ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម (២០០៥)
11. ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៩)
12. ច្បាប់ស្ដីពីពន្ធដារ (១៩៩៧)
13. IFC (2019). Exploring the opportunities for women-owned SMEs in Cambodia
14. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (២០១៩) សេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយស្ដីពីការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ២០១៩-២០២៩
15. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម (២០១៩) ស្ថានភាពបច្ចុប្បន្ននៃ SMEs ក្នុងការផ្ដល់ហិរញ្ញប្បទានជូន MSME នៅកម្ពុជា
16. វិទ្យាស្ថានជាតិស្ថិតិ (២០១៥) ការអង្កេតចន្លោះជំរឿនសេដ្ឋកិច្ចនៅកម្ពុជា ២០១៤ អាចរកមើលបាននៅឯ៖ https://www.stat.go.jp/info/meetings/cambodia/pdf/c14ana02.pdf
17. ប្រកាសលេខ ១៩៨ MIH/2016 ស្ដីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ និងសហគ្រាស ២០១៦ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។
18. ប្រកាសលេខ ៤៤៨ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណា ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ (២០១៧) ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។
19. រាជរដ្ឋាភិបាលកម្ពុជា (២០១៨) យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព៖ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។
20. រាជរដ្ឋាភិបាលកម្ពុជា (២០១៥) គោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជា ២០១៥-២០២៥
21. Sokhorng, C. (2017). "SMEs look for help against imports", The Phnom Penh Post, http://www.phnompenhpost.com/business/smes-look-help-against-imports
22. World Bank (2017). Enterprise surveys: Cambodia country highlights 2016 (English). Enterprise surveys country highlights. Washington, D.C. : World Bank Group. http://documents.worldbank.org/curated/en/468691505112768371/Enterprise-surveys-Cambodia-country-highlights-2016

# ជំពូកទី ២

# ការអនុវត្តក្នុងការចុះបញ្ជី MSME ក្នុងតំបន់អាស៊ាន៖ ករណីសិក្សាពីប្រទេសសិង្ហបុរី ម៉ាឡេស៊ី ថៃ និងមីយ៉ាន់ម៉ា

# I. សេចក្តីផ្តើម

ការដាក់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម (MSMEs) ទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ គឺមានសារៈសំខាន់ណាស់ដើម្បីលើកកម្ពស់កំណើនឧស្សាហកម្ម នៅក្នុងបណ្តាប្រទេសក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ ការដាក់ MSME ចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធតាមរយៈការចុះបញ្ជីអាជីវកម្ម ក៏អាចពង្រឹងលទ្ធភាពរបស់ពួកគេក្នុងការចូលទៅកាន់ទីផ្សារ និងទទួលបានធនធានហិរញ្ញវត្ថុបានមកពេលសមាហរណកម្មសង្វាក់តម្លៃថ្នាក់តំបន់ និងអន្តរជាតិផងដែរ (Giorgi and Rahman, 2013)។ម្យ៉ាងទៀត ការចុះបញ្ជីនេះក៏អាចនាំយកឱកាសបន្ថែមក្នុងការគាំទ្រការអភិវឌ្ឍអាជីវកម្ម ជូនដល់សហគ្រិន MSME រួមទាំងការលើកលែងពន្ធ និងការបន្ធូរបន្ថយពន្ធ ក៏ដូចជាការឧបត្ថម្ភទុន សម្រាប់ការធានាគុណភាពផលិតផល និងការទទួលស្គាល់គុណភាពផងដែរ។ បន្ថែមលើនេះ ការដាក់ MSME ចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ក៏ជួយបង្កើនទំនុកចិត្តពីដៃគូអាជីវកម្ម និងដៃគូរដ្ឋាភិបាល ផងដែរដែលមានន័យថា MSME នឹងមានកង្វល់កាន់តែតិចក្នុងការខ្លាចរដ្ឋាភិបាលក្នុងមូលដ្ឋានបិទអាជីវកម្មរបស់ខ្លួន ដោយសារតែខ្វះព័ត៌មានស្តីពីភាពអនុលោមតាមច្បាប់ (pp. Mel, Mckenzie and Woodruff, 2013)។ ម្យ៉ាងទៀតក៏មានភស្តុតាងបង្ហាញឲ្យឃើញថា ការដាក់ MSME ចូលទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ អាចជួយបង្កើនចំណូលដុលរបស់សហគ្រាស ដែលជួយពង្រីកលំហហិរញ្ញវត្ថុរបស់ MSME ឲ្យវិនិយោគនៅក្នុងផ្នែកការស្រាវជ្រាវ និងអភិវឌ្ឍ និងការកសាងសមត្ថភាពនិយោជិត (Rand and Torm, 2012)។

នៅក្នុងតំបន់អាស៊ាន ប្រទេសជាច្រើនរួមមានដូចជាសិង្ហបុរី ម៉ាឡេស៊ី ថៃ និងមីយ៉ាន់ម៉ា កំពុងអនុវត្តកំណែទម្រង់ដើម្បីធ្វើឲ្យនីតិវិធីដាក់ MSME ទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ មានលក្ខណៈជាប្រព័ន្ធ និងមានទំនើបកម្ម។ ឧទាហរណ៍ រដ្ឋាភិបាលសិង្ហបុរី បានដាក់ឲ្យមានគេហទំព័រ "អាជ្ញាប័ណ្ណមួយ" ("License One") តាមអនឡាញសម្រាប់ការចុះបញ្ជីអាជីវកម្ម និងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ តាមរយៈច្រកផ្លូវអនឡាញទោលតែមួយ។ វេទិកាតាមអនឡាញនេះ បានយកទីភ្នាក់ងាររដ្ឋាភិបាលចំនួន ៤១ មកដាក់នៅក្រោមដំបូលតែមួយ ដែលទទួលបន្ទុកលើការចុះបញ្ជី MSME ផ្តោតលើទិដ្ឋភាពផ្សេងៗគ្នា។ ច្រកទ្វារគេហទំព័រនេះ ជារឿយៗត្រូវបានគេហៅថា ជាដំបូលឌីជីថលនៃការចុះបញ្ជី MSME ក្នុងប្រទេសសិង្ហបុរី (Government of Singapore, 2017)។ ស្រដៀងគ្នានេះដែរ រដ្ឋាភិបាលម៉ាឡេស៊ី បានធ្វើកំណែទម្រង់ដំណើរការនៃ ការចុះបញ្ជីអាជីវកម្មតាមរយៈការដាក់សម្ពោធ "Malaysia Biz" ក្នុងឆ្នាំ ២០១៦ ដែលជាច្រកទ្វារចុះបញ្ជីអាជីវកម្មសំចតតែមួយតាមអនឡាញ អនុញ្ញាតឲ្យការចុះបញ្ជីអាជីវកម្មអាចត្រូវបានធ្វើឡើងតាមអនឡាញ (SME Corp. Malaysia, 2017)។ ដូចគ្នានេះដែរ ប្រទេសថៃបានសម្រួលដំណើរការចុះបញ្ជីអាជីវកម្ម ឲ្យមានភាពងាយស្រួលតាមរយៈការបន្សីនីតិវិធីជាការតម្រូវចាប់តាំងពីឆ្នាំ ២០១៧ មក។ បច្ចុប្បន្ន MSME របស់ថៃអាចជ្រើសរើស ការចុះបញ្ជីអាជីវកម្មតាមអនឡាញ ឬតាមសាខាថ្នាក់ខេត្តនៃនាយកដ្ឋានអភិវឌ្ឍអាជីវកម្ម (OECD/ERIA, 2018)។ ស្រដៀងគ្នានេះដែរ ប្រទេសមីយ៉ាន់ម៉ាបានអនុវត្តកំណែទម្រង់ដើម្បីសម្របសម្រួលដំណើរការចុះបញ្ជីអាជីវកម្ម ឧទាហរណ៍ដូចជាតាមរយៈការលុបបំបាត់ការតម្រូវជាច្រើន ដូចជាឯកសារយោង លិខិតថ្កោលទោស និងមូលធនអប្បបរមាសម្រាប់ការចុះបញ្ជី MSME ជាដើម (OECD/ERIA, 2018)។ រដ្ឋាភិបាលមីយ៉ាន់ម៉ាក៏ដាក់ឲ្យមានច្រកទ្វារការចុះបញ្ជីតាមអនឡាញឈ្មោះ "Myanmar Companies Online" (MyCo) ក្នុងឆ្នាំ ២០១៨ ដោយក្នុងនោះក្រុមហ៊ុននានាអាចចុះបញ្ជីអាជីវកម្មរបស់ខ្លួនតាមអនឡាញបាន (Government of Myanmar, 2018)។

ថ្វីបើបណ្តាប្រទេសអាស៊ានស្ទើរទាំងអស់ បានដាក់សម្ពោធការព្យាយាមដើម្បីដាក់ការចុះបញ្ជី MSME ទៅជាឌីជីថលក្តី ប៉ុន្តែមានតែប្រទេសសិង្ហបុរីប៉ុណ្ណោះ ដែលបានអនុវត្តច្រកផ្លូវសំចតតែមួយឌីជីថលទោលបាន ដោយក្នុងនោះ ដំណើរការចុះបញ្ជី MSME ទាំងមូល ត្រូវធ្វើឡើងតាមអនឡាញ។ ការអនុវត្តគោលនយោបាយការចុះបញ្ជី MSME តាមអនឡាញយ៉ាងខ្លាំងក្លា ត្រូវបានមើលឃើញថាជាការអនុវត្តល្អដែលគាំទ្រដល់ភាពប្រកួតប្រជែងរបស់ MSME និងពង្រឹងតម្លាភាពនៅក្នុងបរិស្ថានអាជីវកម្ម (ASEAN, 2017)។ ប្រទេសសិង្ហបុរីបានទទួលយកគំរូការចុះបញ្ជីតាមឌីជីថលដែលអនុញ្ញាតឲ្យការចុះបញ្ជីអាជីវកម្មអាចធ្វើឡើងបាននៅក្រោមអធិបតីភាពនៃអាជ្ញាធរនិយ័តកម្មគណនេយ្យ និងសាជីវកម្ម (ACRA)។ ប្រទេសម៉ាឡេស៊ីគឺជាប្រទេសមួយទៀតក្នុងតំបន់អាស៊ានដែលបានចាត់វិធានការយ៉ាងខ្លាំងក្លាសម្រាប់ការចុះបញ្ជីអាជីវកម្មតាមឌីជីថល នៅក្នុងនាយកដ្ឋាននានាជាច្រើនរបស់រដ្ឋាភិបាល (OECD/ERIA, 2018)។ ទោះយ៉ាងនេះក្តី បណ្តាប្រទេសអាស៊ានដទៃទៀតដូចជាប្រទេសថៃ ប្រទេសមីយ៉ាន់ម៉ា និងប្រទេសកម្ពុជាជាដើមនៅពុំទាន់កើតសេវាចុះបញ្ជី MSME សំចតតែមួយដែលមាន លក្ខណៈឌីជីថលពេញទាំងស្រុងនៅឡើយទេ។ ថ្វីបើប្រទេសទាំងនេះបានណែនាំឲ្យមាន គម្រោងចុះបញ្ជីតាមឌីជីថលផ្សេងៗ មួយចំនួនក្តី ប៉ុន្តែដំណើរការចុះបញ្ជីនៅតែមានភាពរាយប៉ាយ ហើយស្ថិតក្រោមការគ្រប់គ្រងពីនាយកដ្ឋានផ្សេងៗរបស់រដ្ឋាភិបាល ដោយពុំមានការសម្របសម្រួលខ្លាំងក្លា។ នីតិវិធីសម្រាប់ការចុះបញ្ជី MSME ជារឿយៗ នៅពុំទាន់មានការបកស្រាយបញ្ជាក់ច្បាស់លាស់ សម្រាប់សហគ្រិន MSME នៅឡើយ។ ជារឿយៗ សហគ្រិន MSME ត្រូវបានតម្រូវឲ្យអនុវត្តតាមដំណើរការ ដែលត្រូវចំណាយប្រាក់ និងពេលវេលាអស់ច្រើនក្នុងការបំពេញឯកសារមិនមានស្តង់ដាររួម ហើយត្រូវប្រឈមជាមួយវិធានរដ្ឋបាល ផ្សេងៗ

ជាច្រើន ដែលបង្កើតឲ្យមានឧបសគ្គរាំង ក្នុងការចាប់ផ្តើមអាជីវកម្មប្រកបដោយប្រសិទ្ធផល នៅក្នុងបណ្តាប្រទេសទាំងនេះ (ASEAN, 2016)។ ដោយហេតុថាវឌ្ឍនភាពក្នុងការដាក់ MSME ទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ មានលក្ខណៈខុសៗគ្នា ក្នុងបណ្តាប្រទេសអាស៊ាន ជាការប្រសើរក្នុងការពិនិត្យមើល លើករណីនៃការអនុវត្ត ក្នុងការចុះបញ្ជី MSME ក្នុងប្រទេសដែលគោលនយោបាយការចុះបញ្ជី ត្រូវបានអនុវត្តតាមវិធីផ្សេងៗគ្នា។ ការយល់ដឹងអំពីការអនុវត្តការចុះបញ្ជីផ្សេងៗគ្នានេះ ក៏អាចជួយបណ្តាប្រទេសនានាដូចជាប្រទេសកម្ពុជាជាដើម ដើម្បីកែលម្អការអនុវត្តគោលនយោបាយការចុះបញ្ជី MSME របស់ខ្លួនផងដែរ។ គោលបំណងចម្បងនៃការសិក្សានេះ គឺដើម្បីពិនិត្យឡើងវិញលើការអនុវត្ត ក្នុងការចុះបញ្ជី MSME ក្នុងបណ្តាប្រទេសដែលមានចំនួន ៤ រួមមាន៖ ម៉ាឡេស៊ី មីយ៉ាន់ម៉ា សិង្ហបុរី និងថៃ។ យើងសង្ឃឹមថាការយល់ដឹងអំពីបទពិសោធន៍របស់បណ្តាប្រទេស អាចមានសារៈប្រយោជន៍ដើម្បីបង្កើន ការចុះបញ្ជី MSME ក្នុងប្រទេសកម្ពុជាឲ្យបានប្រសើរជាអតិបរមា។

## II. វិធីសាស្ត្រ

របាយការណ៍នេះប្រើប្រាស់វិធីសាស្ត្រករណីសិក្សាប្រៀបធៀប ដោយផ្តោតការយកចិត្តទុកដាក់លើប្រព័ន្ធការចុះបញ្ជី MSME ក្នុងប្រទេសម៉ាឡេស៊ី សិង្ហបុរី ថៃ និងមីយ៉ាន់ម៉ា។ ការសិក្សានិងពិនិត្យជាពិសេសទៅលើ ស្ថាប័ន និងទីភ្នាក់ងាររដ្ឋាភិបាល ដែលទទួលខុសត្រូវក្នុងការចុះបញ្ជី MSME ក្នុងប្រទេសនីមួយៗ តាមរយៈការផ្តោតការយកចិត្តទុកដាក់ លើកំណែទម្រង់គោលនយោបាយ និងយន្តការផ្នែកស្ថាប័ន។ របាយការណ៍នេះក៏ព្យាយាមពិនិត្យឡើងវិញ លើដំណើរការចុះបញ្ជី MSME ក្នុងប្រទេសនីមួយៗ ជាពិសេសគឺអង្កេតទៅលើការអនុវត្តល្អ និងបញ្ហាប្រឈមដែលអាចពាក់ព័ន្ធសម្រាប់ករណីប្រទេសកម្ពុជា។

ការសិក្សានេះផ្តោតការយកចិត្តទុកដាក់លើប្រទេសចំនួនបួន ដែលមានកម្រិតការសម្របសម្រួលគោលនយោបាយ MSME ខុសៗគ្នា។ ប្រទេសសិង្ហបុរី គឺជាប្រទេសមួយ ក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់អាស៊ាន ដែលមានច្បាប់ និងនីតិវិធីមានប្រសិទ្ធផលខ្ពស់បំផុតពាក់ព័ន្ធជាមួយការចុះបញ្ជីអាជីវកម្ម ដូចជាសេវាសំចតតែមួយតាមអនឡាញ សម្រាប់ការចុះបញ្ជីអាជីវកម្មជាដើម។ ការអនុវត្តប្រហាក់ប្រហែលគ្នានេះ ក៏ឃើញមាននៅក្នុងប្រទេសម៉ាឡេស៊ីផងដែរ។ បន្ថែមលើនេះ ប្រទេសសិង្ហបុរីនិង ម៉ាឡេស៊ី គឺជាប្រទេសទាំងពីរក្នុងតំបន់អាស៊ាន ដែលមានកម្រិតការសម្របសម្រួលផ្នែកគោលនយោបាយពាក់ព័ន្ធជាមួយ MSME កម្រិតខ្ពស់បំផុត នៅតាមទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទាំងអស់ (OECD/ERIA, 2018)។ និយ័តកម្មដែលមានលក្ខណៈអំណោយផល ចំពោះអាជីវកម្ម បានជួយដល់ប្រទេសម៉ាឡេស៊ី និងសិង្ហបុរីឲ្យរក្សាបានពិន្ទុខ្ពស់ នៅក្នុងសន្ទស្សន៍ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម របស់ធនាគារពិភពលោក។ ដោយហេតុនេះ ការសិក្សាលើប្រទេសទាំងពីរនេះ អាចផ្តល់គំនិតមួយចំនួន ទាក់ទងជាមួយការអនុវត្តល្អ ក្នុងការចុះបញ្ជី MSME។

ផ្ទុយទៅវិញ ប្រទេសថៃស្ថិតក្នុង "ដំណាក់កាលមធ្យម" បើនិយាយអំពីការសម្របសម្រួល ក្នុងការអនុវត្តគោលនយោបាយ MSME ប្រកបដោយភាពខ្ពះខ្វែងខ្ពស់។ ប្រទេសនេះបានធ្វើការកែលម្អ សំខាន់ៗ ជាច្រើននៅក្នុងសន្ទស្សន៍ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម របស់ធនាគារពិភពលោក ហើយបានហក់ចេញពីលំដាប់ថ្នាក់ទី ៤៦ ក្នុងឆ្នាំ ២០១៧ មុខជាប់លំដាប់ទី ២៧ ក្នុងឆ្នាំ ២០១៨ (រូបភាពខាងក្រោម)។ ថ្វីបើរដ្ឋាភិបាលថៃបានដាក់ឲ្យមានការចុះបញ្ជី អេឡិចត្រូនិចតាមអនឡាញក្នុងឆ្នាំ ២០១៣ ក្តី ប៉ុន្តែគេនៅតែពុំអាចបញ្ចប់ដំណើរការចុះបញ្ជីអាជីវកម្មទាំងមូល តាមរយៈច្រកទ្វារឌីជីថលទោលតែមួយនោះឡើយ។ នីតិវិធីជាក់លាក់មួយចំនួន នៅតែទាមទារឲ្យមកបំពេញ នៅការិយាល័យរដ្ឋាភិបាលមួយចំនួន (OECD/ERIA, 2018)។ បទពិសោធន៍របស់ប្រទេសថៃក្នុងការកែលម្អដំណើរការចុះបញ្ជីតាមអេឡិចត្រូនិចក៏ធ្វើឲ្យប្រទេសនេះ គឺជាករណីសិក្សាគួរជាទីចាប់អារម្មណ៍សម្រាប់ការសិក្សារបស់យើងនាពេលនេះផងដែរ។

ប្រទេសមីយ៉ាន់ម៉ាគឺជារដ្ឋសមាជិកអាស៊ាន ដែលស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ MSME ហើយពិន្ទុរបស់ប្រទេសនេះទាក់ទងជាមួយសន្ទស្សន៍ភាពងាយស្រួលធ្វើអាជីវកម្មគឺជាប់លំដាប់ថ្នាក់លេខ ១៧១ ក្នុងចំណោមប្រទេសទាំង ១៩០ ដែលត្រូវបានវាយតម្លៃក្នុងឆ្នាំ ២០១៩។ ប្រទេសនេះនៅមិនទាន់បានបង្កើតប្រព័ន្ធដើម្បីគាំទ្រ ដល់ការដាក់ MSME ទៅក្នុងប្រព័ន្ធសេដ្ឋកិច្ចដែលមានលក្ខណៈសាមញ្ញងាយស្រួលនោះឡើយ។ ការទទួលបានអាជ្ញាប័ណ្ណអាជីវកម្ម ទើបគេឲ្យត្រូវឆ្លងកាត់ ទីភ្នាក់ងាររដ្ឋាភិបាលជាច្រើន (Berkel.H.et al, 2018)។ ថ្វីបើរដ្ឋាភិបាលមីយ៉ាន់ម៉ា បានដាក់ឲ្យមានប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមអេឡិចត្រូនិច ក្នុងឆ្នាំ ២០១៨ ក្តី ប៉ុន្តែការផ្តួចផ្តើមគំនិតផ្នែកគោលនយោបាយនេះ គ្រាន់តែឆ្លើយតបចំពោះបញ្ហា នៃការចុះបញ្ជីសាជីវកម្មប៉ុណ្ណោះ។ ការចុះបញ្ជីជាមួយនាយកដ្ឋានរដ្ឋាភិបាលដទៃទៀត ដូចជានាយកដ្ឋានពន្ធដារជាដើមគឺនៅត្រូវការឯកសារជាច់ដោយឡែកជាច្រើនទៀត ព្រមទាំងដំណើរការនៃការដាក់ពាក្យ ដ៏អូសបន្លាយ។ ការពិនិត្យលើករណីប្រទេស មីយ៉ាន់ម៉ា ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍគោលនយោបាយ MSME នេះក៏អាចជាចំណុចពិគ្រោះមួយសម្រាប់ករណីប្រទេសកម្ពុជាផងដែរ។

រូបភាពទី ១ ៖ ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម ( ១ = និយ័តកម្មអំណោយផលដល់អាជីវកម្មខ្លាំងបំផុត )




*ប្រភពឯកសារ៖ ទិន្នន័យរបស់ធនាគារពិភពលោក ការធ្វើអាជីវកម្ម។ សម្គាល់៖ សេដ្ឋកិច្ចទាំងនេះត្រូវបានចាត់ចំណាត់ថ្នាក់ផ្អែកលើភាពងាយស្រួលក្នុងការធ្វើអាជីវកម្មដោយមានចំណាត់ថ្នាក់ពី ១ ដល់ ១៩០ ( ១ = និយ័តកម្មមានលក្ខណៈអំណោយផលដល់អាជីវកម្មខ្លាំងបំផុត )។ ការប្រៀបធៀបត្រូវបានធ្វើឡើងនៅក្នុងសេដ្ឋកិច្ចចំនួន ១៨៥ ប្រទេសក្នុងឆ្នាំ ២០១៣ សេដ្ឋកិច្ចចំនួន ១៨៩ ប្រទេសក្នុងឆ្នាំ ២០១៤-២០១៦ និងចំនួន ១៩០ ប្រទេសក្នុងឆ្នាំ ២០១៧-២០១៩។*

# III. ការចុះបញ្ជី MSME ក្នុងប្រទេសសិង្ហបុរី ម៉ាឡេស៊ី ថៃ និងមីយ៉ាន់ម៉ា

## ១. ប្រទេសសិង្ហបុរី

ប្រទេសសិង្ហបុរីបានឈានដល់ដំណាក់កាលជឿនលឿននៃការចុះបញ្ជី MSME ជាលទ្ធផលនៃកំណែទម្រង់គោលនយោបាយ និងស្ថាប័នសម្របសម្រួល MSME ដ៏រឹងមាំជាច្រើន។ ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម ( MTI ) គឺជានាយកដ្ឋានរដ្ឋាភិបាលចម្បងដែលទទួលខុសត្រូវក្នុងការសម្របសម្រួលលើគោលនយោយចុះបញ្ជី MSME។ ក្រសួងនេះធ្វើការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងាររដ្ឋាភិបាលដទៃទៀតក្រុមប្រឹក្សាភិបាលផ្នែកច្បាប់ អ្នកតំណាងរបស់ MSME វិស័យសិក្សាស្រាវជ្រាវ និងសង្គមស៊ីវិល ដើម្បីគាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍ MSME (OECD/ERIA, 2018)។ MTI បានបង្កើត Enterprise Singapore (ESG) ដែលពីមុនមកមានឈ្មោះថា បទដ្ឋាន ផលិតភាព នវានុវត្តន៍ និងកំណើន (Standard, Productivity, Innovation and Growth) (SPRING) ដែលជាស្ថាប័នមួយទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍ MSME ក្នុងប្រទេសសិង្ហបុរីក្នុងគោលវិធីការលក់ដុំ។ បន្ថែមលើនេះ គោលវិធីដែលត្រូវបានកែសម្រួលឲ្យសាមញ្ញសម្រាប់ការចុះបញ្ជីក្រុមហ៊ុន ការដាក់ពាក្យបង់ពន្ធ និងទម្រង់សន្តិសុខសង្គមត្រូវបានតម្លើងឲ្យមាននៅក្នុងប្រទេសសិង្ហបុរី។ គោលនយោបាយ និងកម្មវិធីទាំងអស់ត្រូវបានពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ ( OECD/ERIA, 2018 )។

ដើម្បីលើកកម្ពស់ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម រដ្ឋាភិបាលសិង្ហបុរីបានដាក់ឲ្យប្រើប្រាស់វេទិកាសំចតតែមួយកន្លែងបែបឌីជីថលដើម្បីសម្របសម្រួលដល់ការចុះបញ្ជី MSME។ វេទិកានេះបើកទូលាយមិនត្រឹមតែសម្រាប់ MSMEs តែប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អាជីវកម្មគ្រប់ប្រភេទផងដែរ ដែលគាំទ្រដល់ការចុះបញ្ជីតាមអនឡាញ និងការទទួលបានអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតរបស់ពួកគេ រួមទាំងការចុះបញ្ជីពន្ធផងដែរ។

ការដាក់ឲ្យមានវេទិកានេះមិនត្រឹមតែជួយសន្សំពេលវេលា និងថ្លៃចំណាយប្រតិបត្តិការតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានជួយលើកកម្ពស់ភាពស៊ីសង្វាក់ និងតម្លៃភាពនៃបរិស្ថានគោលនយោបាយសម្រាប់ប្រតិបត្តិការអាជីវកម្មយ៉ាងសន្ទឹកសន្ធាប់ផងដែរ ( World Bank, 2019a )។ ដើម្បីប្រតិបត្តិការវេទិកាសំចតតែមួយកន្លែងបែបឌីជីថលសម្រាប់ការចុះបញ្ជីអាជីវកម្មនេះ ស្ថាប័នសម្របសម្រួលអន្តរទីភ្នាក់ងារមួយដែលមានឈ្មោះថា អាជ្ញាធរគណនេយ្យ និង និយ័តកម្មសារជីវកម្ម (Accounting and Corporate Regulatory Authority) (ACRA) ត្រូវបានបង្កើតឡើង។ ACRA សហការជាមួយទីភ្នាក់ងាររដ្ឋាភិបាល និង អ្នកពាក់ព័ន្ធដទៃទៀតក្នុងប្រទេសសិង្ហបុរី ដើម្បីអភិវឌ្ឍសេវាបែបឌីជីថលចម្រុះដើម្បីអនុញ្ញាតឲ្យក្រុមហ៊ុននានាអាចចុះបញ្ជីអាជីវកម្មរបស់ខ្លួនបានកាន់តែងាយស្រួល និងឆ្លើយតបតាមកាតព្វកិច្ចផ្នែកនិយ័តកម្មរបស់ខ្លួន (ACRA, 2018)។ ឧទាហរណ៍ អាជីវកម្មទើបចាប់ផ្តើមថ្មីអាចចុះបញ្ជីសម្រាប់សេវាដូចខាងក្រោម ( ប្រអប់ខាងក្រោម ) នៅក្នុងវេទិកាសំចតតែមួយកន្លែង ប្រតិបត្តិការដោយ ACRA ដែលរួមមានទាំងការរក្សាទុកដូម៉េនតាមអនឡាញមួយសម្រាប់ក្រុមហ៊ុន ការបើកគណនីធនាគារ ការចុះបញ្ជីសម្រាប់កាតព្វកិច្ចពន្ធ ការដាក់ឲ្យគណនីកែសម្រួលរបស់ខ្លួនមានសកម្មភាព និងការចុះឈ្មោះចូលទៅក្នុងប្រព័ន្ធផ្តល់ព័ត៌មានអាជីវកម្មរបស់រដ្ឋាភិបាលស្តីពីបច្ចុប្បន្នភាពគោលនយោបាយចុងក្រោយបំផុត។

| ប្រអប់ទី ១ វេទិកាសំចកតែមួយកន្លែងបែបឌីជីថលនៅ ACRA |
|---|
| អាជីវកម្មថ្មីៗដែលបានចុះបញ្ជីជាមួយ ARCA បានទទួលជម្រើសដើម្បីចុះបញ្ជីសេវាដូចខាងក្រោម៖<br>• ការរក្សាឈ្មោះដូម៉េន<br>• ការបើកគណនីធនាគារ<br>• ចុះបញ្ជីសម្រាប់ពន្ធទំនិញ និងសេវាកម្ម<br>• ដាក់ឲ្យគណនីគយមានសកម្មភាព<br>• ចុះឈ្មោះចូលទៅក្នុងព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិចដោយឥតគិតថ្លៃ<br>• ចុះឈ្មោះចូលក្នុងប្រព័ន្ធគឿនព័ត៌មាន GeBiz<br><br>ប្រសិនបើអ្នកដាក់ពាក្យចុះឈ្មោះប្រើប្រាស់សេវាណាមួយខាងលើ ព័ត៌មានលម្អិតសម្រាប់ការដាក់ពាក្យនឹងត្រូវបញ្ជូនបន្ត ដោយ ACRA ទៅកាន់នាយកដ្ឋានរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីធ្វើការចុះបញ្ជីយ៉ាងឆាប់រហ័ស។ |

*ប្រភព៖: Dayan and Bolislis, 2017 and ACRA*

ការចុះបញ្ជីអាជីវកម្មនៅប្រទេសសិង្ហបុរី រួមមាន ៣ ជំហាន ដោយជំហានទាំងអស់នេះអាចបំពេញតាមអនឡាញ តាមរយៈច្រកផ្លូវទោលតែមួយ ( World Bank , 2019b )។ ជាមធ្យមត្រូវចំណាយរយៈពេល ៣ ថ្ងៃ ដើម្បីបំពេញដំណើរការ ហើយសហគ្រាសអាចចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន យ៉ាងឆាប់រហ័សបន្ទាប់ពីនោះ។

សម្រាប់ជំហានទីមួយ អាជីវកម្មថ្មីចាំបាច់ត្រូវផ្តល់ឈ្មោះ និងដាក់វិញ្ញាបនបត្របញ្ជាក់អាជីវកម្ម និងលេខពន្ធរបស់ក្រុមហ៊ុនខ្លួនមកកាន់ ACRA។ នៅដំណាក់កាលនេះក្រុមហ៊ុនអាចរក្សានាមករណ៍ដូម៉េនរបស់ខ្លួន ចុះបញ្ជីសម្រាប់ពន្ធលើទំនិញ និងសេវា (GST) ចុះឈ្មោះទទួលព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិច ដែលពាក់ព័ន្ធ និងចុះឈ្មោះប្រើសេវាទទួលព័ត៌មានអេឡិចត្រូនិច ស្តីពីឱកាសលទ្ធកម្មថ្មីៗបំផុត របស់រដ្ឋាភិបាល បន្ថែមលើការដាក់គណនីគយឲ្យសកម្ម និងដាក់ពាក្យសុំគណនីធនាគារសាជីវកម្ម។ ដំណើរការទាំងអស់នេះត្រូវចំណាយពេលតិចជាងមួយថ្ងៃដើម្បីបំពេញដោយហេតុថា កិច្ចការទាំងអស់នេះសុទ្ធតែធ្វើបាន តាមរយៈវេទិកាអនឡាញ ហើយត្រូវចំណាយសរុបចំនួន ២៣០ ដុល្លារអាមេរិក។ សម្រាប់ជំហានទីពីរ អាជីវកម្មចាំបាច់ត្រូវបង្កើតត្រាក្រុមហ៊ុន ដែលអាចបញ្ជាទិញតាមអនឡាញបានផងដែរ។ ទោះយ៉ាងនេះក្តី ការមានត្រាក្រុមហ៊ុនគឺពុំមែនជាកាតព្វកិច្ចត្រូវតែបំពេញ សម្រាប់គ្រប់អាជីវកម្មនោះទេ ហើយការសម្រេចចិត្តក្នុងការមានត្រា ឬមិនមានគឺអាស្រ័យលើក្រុមហ៊ុនជាអ្នកសម្រេច។ ចំពោះជំហានទីបី អាជីវកម្មចាំបាច់ត្រូវចុះឈ្មោះទទួលយកសេវាធានារ៉ាប់រង ការផ្តល់សំណងដល់និយោជិត ជាមួយទីភ្នាក់ងារធានារ៉ាប់រងណាមួយ។ ជំហាននេះក៏អាចបំពេញតាមអនឡាញបានដែរ។ យោងតាម ACRA ម្ចាស់អាជីវកម្មថ្មី អាចទិញគម្រោងធានារ៉ាប់រងសម្រាប់និយោជិតរបស់ខ្លួន តាមច្រកទ្វារអនឡាញឈ្មោះ BizFile+។ នៅខែតុលា ឆ្នាំ ២០១៧ សេវាធានារ៉ាប់រងការផ្តល់សំណងគ្រោះថ្នាក់ការងារតាមអនឡាញថ្មី ត្រូវបានដាក់ឲ្យមានជាផ្នែកមួយនៃកិច្ចខិតខំ ដើម្បីជំរុញដំណើរការចុះបញ្ជីអាជីវកម្មតាមអនឡាញដោយរលូនបន្ថែមទៀត។

តារាងទី ១ ៖ ជំហានដើម្បីចុះបញ្ជីអាជីវកម្មក្នុងប្រទេសសិង្ហបុរី

| ជំហាន | ដំណើរការ | ស្ថាប័ន/ ទីភ្នាក់ងារ | ឯកសារដែលត្រូវទទួលបាន | រយៈពេល និង ថ្លៃសេវា |
|---|---|---|---|---|
| ជំហានទី ១ | ការចុះបញ្ជីតាមអនឡាញរួមទាំងការបង្កើតឈ្មោះក្រុមហ៊ុន និងការដាក់លេខសាជីវកម្មក្រុមហ៊ុន និងពន្ធ | អាជ្ញាធរគណនី និងនិយ័តកម្មសាជីវកម្ម (ACRA) | កក់ឈ្មោះដូម៉េន ពន្ធទំនិញ និងសេវា (GST) ដែលបានចុះបញ្ជី ដាក់គណនីគយឲ្យសកម្ម និងទទួលបានគណនីធនាគារសាជីវកម្ម | តិចជាងមួយថ្ងៃវិធីតាមអនឡាញ)<br><br>ថ្លៃសេវា៖<br>៣១៥ ដុល្លារសិង្ហបុរី (២៣០ ដុល្លារអាមេរិក) |
| ជំហានទី ២ | បង្កើតត្រាក្រុមហ៊ុន (មិនមែនជាកាតព្វកិច្ច) | អ្នកធ្វើត្រា | ត្រាក្រុមហ៊ុន | មួយថ្ងៃ<br><br>ថ្លៃសេវា៖<br>៧០ ដុល្លារសិង្ហបុរី (៥១ ដុល្លារអាមេរិក) |
| ជំហានទី ៣ | ចុះឈ្មោះទទួលសេវាធានារ៉ាប់រងសំណងនិយោជិតជាមួយទីភ្នាក់ងារធានារ៉ាប់រង | ទីភ្នាក់ងារធានារ៉ាប់រង | | មួយថ្ងៃតាមអនឡាញ ឥតគិតថ្លៃ |

*ប្រភព៖: ប្រភព៖ អាជ្ញាធរគណនេយ្យ និងនិយ័តកម្មសាជីវកម្ម (ACRA), ប្រទេសសិង្ហបុរី*

## ២. ប្រទេសម៉ាឡេស៊ី

ការចុះបញ្ជីអាជីវកម្មក្នុងប្រទេសម៉ាឡេស៊ី ទាំងសម្រាប់សហគ្រាសធំ និងការចុះបញ្ជី MSME រួមមានប្រាំបួនជំហាន ហើយត្រូវចំណាយរយៈពេលចន្លោះពី ១២ ដល់ ១៥ ថ្ងៃធ្វើការដើម្បីបំពេញ ដោយក្នុងនោះរួមមានការចុះបញ្ជីជាមួយនាយកដ្ឋាននានារបស់រដ្ឋាភិបាល។ រដ្ឋាភិបាលម៉ាឡេស៊ីបានដាក់ឲ្យប្រើប្រាស់ មជ្ឈមណ្ឌលសេវាសំចតតែមួយកន្លែង តាមអនឡាញជាផ្លូវការ ដើម្បីចុះបញ្ជីសហគ្រាស ដែលត្រូវបានប្រតិបត្តិការដោយបេសកកម្មក្រុមហ៊ុនម៉ាឡេស៊ី (CCM)។ ទោះយ៉ាងណាក្តី ពុំមែនគ្រប់នីតិវិធីទាំងអស់ ត្រូវអនុវត្តតាមអនឡាញទាំងអស់នោះទេ។ សម្រាប់ជំហានទីមួយ សហគ្រាសចាំបាច់ត្រូវកំណត់ និងរក្សាឈ្មោះមួយដាក់មកកាន់ CCM។ ដំណើរការអាចធ្វើឡើងតាមអនឡាញដោយត្រូវចំណាយពេលមួយថ្ងៃ ហើយអស់ថ្លៃ ១២ ដុល្លារអាមេរិក។ នៅពេលឈ្មោះដែលបានដាក់ស្នើ ត្រូវបានអនុម័ត សហគ្រាសចាំបាច់ត្រូវដាក់ឯកសារ ជាការតម្រូវដទៃទៀតតាមអនឡាញ។ សហគ្រាសក៏គួរបើកគណនីធនាគារ រួចចុះបញ្ជីជាមួយនាយកដ្ឋានពន្ធដារ ដែលរួមមានការចុះបញ្ជីដើម្បីបង់ពន្ធសេវាទូទៅ (GST) និងពន្ធលើប្រាក់ចំណូល។ សហគ្រាសចាំបាច់ត្រូវចុះបញ្ជីជាមួយមូលនិធិថវិកានិយោជិត (employee Provident fund) និងមូលនិធិសន្តិសុខសង្គម។ បន្ថែមលើនេះ ប្រសិនបើសហគ្រាសត្រូវប្រតិបត្តិការក្នុងតំបន់រាជធានីកូឡាឡាំពួរ ក្រុមហ៊ុនចាំបាច់ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណមួយទៀត ពេលអាជ្ញាធររាជធានី សម្រាប់បរិវេណអាជីវកម្មរបស់ខ្លួន។ ម្យ៉ាងទៀតត្រូវកត់សម្គាល់ផងដែរថា ចាំបាច់ត្រូវមានជំហ៊ានបន្ថែម សម្រាប់ធុរជនជាស្ត្រីរៀបការរួច។

តារាងទី ២ ៖ ជំហានដើម្បីចុះឈ្មោះអាជីវកម្មក្នុងប្រទេសម៉ាឡេស៊ី

| ជំហាន | ដំណើរការ | ស្ថាប័ន/ ទីភ្នាក់ងារ | ឯកសារដែល ត្រូវទទួលបាន | រយៈពេល និង ថ្លៃសេវា |
|---|---|---|---|---|
| ជំហានទី ១ | រក្សាឈ្មោះក្រុមហ៊ុនដាក់ជូនទៅបេសកកម្មក្រុមហ៊ុនម៉ាឡេស៊ី (CCM) នៅកន្លែងសំចតតែមួយតាមអនឡាញ | បេសកម្មក្រុមហ៊ុនម៉ាឡេស៊ី (CCM) | | តិចជាមួយថ្ងៃ<br>(នីតិវិធីតាមអនឡាញ)<br>ថ្លៃសេវា៖ ៥០ រីងហ្គីត (១២ ដុល្លារអាមេរិក) |
| ជំហានទី ២ | លេខាក្រុមហ៊ុនរៀបចំឯកសារក្រុមហ៊ុន | | | ១-៣ ថ្ងៃ<br>ថ្លៃសេវា៖<br>១០០០ រីងហ្គីត (២៤៧ ដុល្លារអាមេរិក) |
| ជំហានទី ៣ | ដាក់ឯកសារចាំបាច់ជូនទៅ CCM តាមគេហទំព័រ សំចតតែមួយកន្លែង<br>(ក្រុមហ៊ុនអាចដាក់ពាក្យតាមអនឡាញក៏បាន) | បេសកម្មក្រុមហ៊ុនម៉ាឡេស៊ី (CCM) | ទទួលបានកញ្ចប់សាជីវកម្មក្រុមហ៊ុន ក៏ដូចជាកញ្ចប់ក្រោយសាជីវកម្ម (ត្រាក្រុមហ៊ុន) ចែករំលែកវិញ្ញាបនបត្រ និងសៀវភៅពាក់ព័ន្ធជាមួយច្បាប់) | |
| ជំហានទី ៤ | បើកគណនីធនាគារ | ធនាគារ | គណនីធនាគារ។ ចាំបាច់ត្រូវចុះបញ្ជីពន្ធទំនិញ និងសេវាកម្ម (GST) | ១ ថ្ងៃ<br>ឥតគិតថ្លៃ |

| ដំហាន | ដំណើរការ | ស្ថាប័ន/ ទីភ្នាក់ងារ | ឯកសារដែល<br>ត្រូវទទួលបាន | រយៈពេល<br>និង ថ្លៃសេវា |
|---|---|---|---|---|
| ដំហានទី ៥ | ចុះបញ្ជីពន្ធទំនិញ និង សេវា (GST) ដើម្បីចុះបញ្ជី GST ក្រុមហ៊ុនចាំបាច់ត្រូវដាក់ទម្រង់ដូចខាងក្រោម<br>- លេខចុះបញ្ជីអាជីវកម្ម<br>អាសយដ្ឋានអ៊ីមែលមាន<br>សុពលភាព ទំនិញផ្គត់ផ្គង់<br>ដែលអាចជាប់ពន្ធសរុប<br>លេខកូដឧស្សាហកម្ម<br>ព័ត៌មានអំពីគណនីធនាគារ | គយម៉ាឡេស៊ី | | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ដំហានទី ៦ | ចុះបញ្ជីសម្រាប់ពន្ធលើប្រាក់ចំណូល និង PAYE | ក្រុមប្រឹក្សាចំណូលដីគោកម៉ាឡេស៊ី (LHDN) | លេខពន្ធប្រាក់ចំណូល | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ដំហានទី ៧ | ចុះបញ្ជីមូលនិធិថវិកានិយោជិត | មូលនិធិថវិកា<br>និយោជិត (KWSP) | វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះនិយោជក និង លេខកូដដាក់ឲ្យដំណើរការ i-Akaun | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ដំហានទី ៨ | ចុះបញ្ជីសន្តិសុខសង្គម | ស្ថាប័នសន្តិសុខសង្គម (SOCSO- Perkeso) | | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ដំហានទី ៩ | ទទួលបានអាជ្ញាប័ណ្ណបរិវេណអាជីវកម្ម។ ដើម្បីអនុវត្តសកម្មភាពអាជីវកម្មក្នុងបរិវេណរាជធានីកូឡាឡាំពួ សហគ្រាសចាំបាច់ត្រូវសុំអាជ្ញាប័ណ្ណបរិវេណអាជីវកម្ម។ អាជ្ញាប័ណ្ណត្រូវបានចេញដោយបេសករាជធានីកូឡាឡាំពួ។ | សាលារាជធានី<br>កូឡាឡាំពួ | | ៥ ថ្ងៃ<br><br>ថ្លៃសេវា៖ ៣ រីងហ្គីត (0,៧២ ដុល្លារអាមេរិក) ក្នុងមួយម៉ែត្រការេ |

### ៣. ប្រទេសថៃ

យោងតាមសន្ទស្សន៍ភាពងាយស្រួលនៃការធ្វើអាជីវកម្មរបស់ធនាគារពិភពលោក ក្នុងចំណោមប្រទេសទាំង ១៩០ដែលត្រូវបានពិនិត្យឡើងវិញ ប្រទេសថៃសម្រេចបានការឈានឡើងយ៉ាងខ្លាំងក្លាដោយប្រទេសនេះជាប់ចំណាត់ថ្នាក់ទី៤៧ក្នុងឆ្នាំ២០១៦ហើយឈានឡើងទៅដល់លំដាប់លេខ ២៧ ក្នុងឆ្នាំ ២០១៩ ជាការបង្ហាញឲ្យឃើញនូវ ភាពប្រសើរឡើងយ៉ាងខ្លាំងក្លា នៅក្នុងបរិស្ថានគោលនយោបាយ ក្នុងការធ្វើអាជីវកម្មក្នុងប្រទេសថៃ។

ទោះយ៉ាងនេះក្តី ប្រទេសថៃនៅពុំទាន់បានបំពេញការផ្លាស់ប្តូរទាំងស្រុង ទៅកាន់សេវាសំចតតែមួយកន្លែងបែបឌីជីថល សម្រាប់ការចុះបញ្ជីអាជីវកម្មនៅឡើយ។ ប្រទេសនេះតម្រូវឲ្យមាន ៦ ជំហាន និងរយៈពេលប្រមាណ ៦ ថ្ងៃធ្វើការសម្រាប់សហគ្រាស ដើម្បីបំពេញដំណើរការចុះបញ្ជីអាជីវកម្ម។ នីតិវិធីមួយចំនួនត្រូវបានអនុវត្តតាមអនឡាញ ចំណែកមួយចំនួនទៀតចាំបាច់ត្រូវធ្វើ ដាក់ស្តែងមិនមែនតាមអនឡាញ។ ឧទាហរណ៍ ថ្វីបើគេអាចធ្វើការចុះបញ្ជីឈ្មោះក្រុមហ៊ុន តាមអនឡាញក្តី ប៉ុន្តែការទូទាត់ថ្លៃសេវាចាំបាច់ទៅធ្វើឡើងដាក់ស្តែងមិនមែនតាមអនឡាញ ដោយអាចទៅតាមទីភ្នាក់ងាររបស់រដ្ឋាភិបាល ឬតាមរយៈធនាគារ។ ការចុះបញ្ជីអាជីវកម្ម ទាំងសម្រាប់សហគ្រាសធុនធំ និងសហគ្រាសធុនតូច និងមធ្យមចាំបាច់ត្រូវអនុវត្តតាមជំហានចំនួន ៧។ នៅជំហានដំបូង សហគ្រាសចាំបាច់ត្រូវជ្រើសរើស និង រក្សាឈ្មោះរបស់ខ្លួនទុកនៅជាមួយនាយកដ្ឋានអភិវឌ្ឍអាជីវកម្មក្នុងក្រសួងពាណិជ្ជកម្ម។ កិច្ចការនេះអាចធ្វើឡើងតាមអនឡាញ ហើយត្រូវចំណាយពេលមួយថ្ងៃធ្វើការដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះអាជីវកម្ម។ ក្នុងជំហានទី ២ សហគ្រាសចាំបាច់ត្រូវផ្តល់ភស្តុតាងបញ្ជាក់អំពីមូលធន ចាំបាច់ត្រូវមានប្រតិបត្តិការអាជីវកម្មក្នុងទម្រង់ជាវិញ្ញាបនបត្រ បញ្ជាក់ការផ្ញើប្រាក់នៅធនាគារ ដាក់ជូនទៅក្រសួងពាណិជ្ជកម្ម។ បន្ទាប់ពីបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះ និងភស្តុតាងនៃការដាក់ប្រាក់បញ្ញើហើយ ជំហានទី ៣ ទាមទារអោយសហគ្រាសត្រូវបង្កើតត្រាសាជីវកម្ម។ ក្នុងដំណាក់កាលទី ៤ សហគ្រាសចាំបាច់ត្រូវដាក់អនុស្សារណៈនៃសមាគម (MoA) ឬលក្ខន្តិកៈក្រុមហ៊ុនជូនទៅក្រសួងពាណិជ្ជកម្មដើម្បីពិនិត្យឡើងវិញ។ ជំហាននេះត្រូវចំណាយពេលជាមធ្យមមួយថ្ងៃ។ ក្នុងដំណាក់កាលទី ៥ បន្ទាប់ពីមានការអនុម័តលើ MoA ដោយក្រសួងពាណិជ្ជកម្មហើយ សហគ្រាសចាំបាច់ត្រូវទូទាត់ប្រាក់ដើម្បីបំពេញដំណើរការចុះបញ្ជីអាជីវកម្ម។ នៅពេលការងារនេះត្រូវបានធ្វើរួច អាជីវកម្មចាំបាច់ត្រូវបន្តទៅចុះបញ្ជីពន្ធជាមួយនាយកដ្ឋានចំណូល។ ទាល់តែនៅក្រោយពេលបានបញ្ចប់ជំហានទាំងអស់នេះរួចរាល់ហើយប៉ុណ្ណោះ ទើបអាជីវកម្មអាចបានទទួលអាជ្ញាប័ណ្ណប្រតិបត្តិការជាស្ថាពរ។

### តារាងទី ៣ ៖ ជំហានដើម្បីចុះឈ្មោះអាជីវកម្មក្នុងប្រទេសថៃ

| ជំហាន | ដំណើរការ | ស្ថាប័ន/ ទីភ្នាក់ងារ | ឯកសារដែលត្រូវទទួលបាន | រយៈពេល និង ថ្លៃសេវា |
|---|---|---|---|---|
| ជំហានទី ១ | ស្វែងរក និងរក្សាឈ្មោះក្រុមហ៊ុនតាមអនឡាញ | នាយកដ្ឋានអភិវឌ្ឍអាជីវកម្មក្រោមក្រសួងពាណិជ្ជកម្ម | វិញ្ញាបនបត្របញ្ជាក់ការរក្សាឈ្មោះ | តិចជាងមួយថ្ងៃ (នីតិវិធីតាមអនឡាញ) |
| ជំហានទី ២ | ដាក់មូលធនបង់ប្រាក់បញ្ញើក្នុងធនាគារ | ធនាគារ | ភស្តុតាងបង្ហាញការដាក់ប្រាក់បញ្ញើ | ១ ថ្ងៃ ឥតគិតថ្លៃ |
| ជំហានទី ៣ | ទទួលបានត្រាសាជីវកម្ម | អ្នកធ្វើត្រា | ត្រាសាជីវកម្ម | ១ ថ្ងៃ ថ្លៃសេវា៖ ៤០០ បាត (១៣ ដុល្លារអាមេរិក) |

| ជំហាន | ដំណើរការ | ស្ថាប័ន/ ទីភ្នាក់ងារ | ឯកសារដែលត្រូវទទួលបាន | រយៈពេល និង ថ្លៃសេវា |
|---|---|---|---|---|
| ជំហានទី ៤ | ទទួលបានការអនុម័តលើអនុស្សរណៈសមាគម (MoA) ដាក់ជូនដើម្បីចុះបញ្ជីក្រុមហ៊ុនជារូបវន្តបុគ្គល (ការចុះបញ្ជីស្ថាព) នៅ មជ្ឈមណ្ឌលសេវាចំណុចទោល សហគ្រិនអាចចុះបញ្ជីក្រុមហ៊ុន ទទួលបាន TIN ចុះបញ្ជីសន្តិសុខសង្គម និងចុះបញ្ជីមូលនិធិផ្តល់សំណងកម្មករ។ឯកសារទាំងអស់ត្រូវបានដាក់ជូន និងពិនិត្យឡើងវិញនៅក្នុងបង្អួចតែមួយ ក្នុងរយៈពេល ១ ថ្ងៃ។ | ការិយាល័យភាពជាដៃគូ និងចុះបញ្ជីក្រុមហ៊ុន នាយកដ្ឋានអភិវឌ្ឍអាជីវកម្ម នៃក្រសួងពាណិជ្ជកម្ម | អនុម័តលើ MoA និងភស្តុតាងបញ្ជាក់ថាក្រុមហ៊ុនជានីតិបុគ្គល | មួយថ្ងៃ<br><br>ថ្លៃសេវាសម្រាប់ការចុះបញ្ជីសមាគមគឺ ៥០០ បាត (១៦ ដុល្លារ)អប្បបរមា ទៅដល់ ២៥ ០០០ បាត (៧៩៨ ដុល្លារ)<br><br>អតិបរមា។ ថ្លៃសេវាចុះបញ្ជីសមាគមត្រូវកើនឡើង ៥០បាតរៀងរាល់មូលធនដើម ១០០ ០០០។ ថ្លៃសេវាអប្បបរមាសម្រាប់ការចុះបញ្ជីក្រុមហ៊ុនគឺ ៥០០០ បាត (១៦០ ដុល្លារ)និងអតិបរមា ២៥០ ០០០ បាត (៧៩៥៨៥ ដុល្លារ)។<br><br>បន្ថែមលើនេះ ទឹកប្រាក់ ៧៥០ បាត (២៣ ដុល្លារ) សម្រាប់តែម វិញ្ញាបនបត្រចុះបញ្ជី ថ្លៃសេវាលិខិតសក្ខីកម្ម និងថ្លៃសេវាឯកសារ។ |
| ជំហានទី ៥ | ការចុះបញ្ជីសម្រាប់ពន្ធលើតម្លៃបន្ថែមការចុះបញ្ជី (VAT) គឺជាកាតព្វកិច្ចសម្រាប់គ្រប់ក្រុមហ៊ុនទាំងអស់នៅពេលចំណូលប្រចាំឆ្នាំលើសរបាកំណត់ក្នុងទឹកប្រាក់ ១,៨ លានបាត (៥៦ ០០០ ដុល្លារ)។ | នាយកដ្ឋានចំណូល | | មួយថ្ងៃ<br><br>មិនគិតប្រាក់ការចុះបញ្ជីអាចធ្វើឡើងតាមអនឡាញ ឬទៅកាន់ការិយាល័យរបស់នាយកដ្ឋានចំណូល។ |
| ជំហានទី ៦ | ចុះបញ្ជីនិយោជិតជាមួយការិយាល័យសន្តិសុខសង្គម | ការិយាល័យសន្តិសុខសង្គម | | ១ ថ្ងៃ<br>មិនគិតប្រាក់ |

### ៤. ប្រទេសមីយ៉ាន់ម៉ា

ការចុះបញ្ជីអាជីវកម្មក្នុងប្រទេសមីយ៉ាន់ម៉ាទាំងសម្រាប់សហគ្រាសធុនធំ និង MSME គឺរួមមាន ១៣ ជំហាន ហើយត្រូវចំណាយពេលប្រមាណ ១៥ថ្ងៃធ្វើការដើម្បីបំពេញដោយរួមមានពាក់ព័ន្ធជាមួយនាយកដ្ឋាននានារបស់រដ្ឋាភិបាល។ទោះយ៉ាងនេះក្តី ការចុះបញ្ជីអាជីវកម្មក្នុងប្រទេសនេះអាចត្រូវចំណាយពេល និងអស់ថ្លៃច្រើនជាង បើធៀបជាមួយសមភាគី ក្នុងតំបន់អាស៊ាន ដែលចូលរួមចំណែកធ្វើឲ្យ ប្រទេសនេះជាប់ចំណាត់ថ្នាក់ទាបនាពេលបច្ចុប្បន្ននៅក្នុងការវាយតម្លៃភាពងាយស្រួល ក្នុងការធ្វើអាជីវកម្ម។

នៅជំហានដំបូងនៃការចុះបញ្ជី សហគ្រាសចាំបាច់ត្រូវធ្វើការពិនិត្យឈ្មោះក្រុមហ៊ុន ដែលអាចត្រូវបានធ្វើឡើងតាមអនឡាញ ឬតាមរយៈការទៅជួបផ្ទាល់នៅអគ្គនាយកដ្ឋានវិនិយោគនិងរដ្ឋបាលក្រុមហ៊ុន (DICA)។ក្នុងជំហានទីពីរ សហគ្រាសចាំបាច់ត្រូវដាក់ឯកសារតាមការតម្រូវទាំងអស់សម្រាប់ការបង្កើតក្រុមហ៊ុនដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី។ ក្នុងដំណាក់កាលទីបី ក្រុមហ៊ុនចាំបាច់ត្រូវមានវិញ្ញាបនប័ត្របោះត្រាដោយមេធាវី ពីក្រុមហ៊ុនច្បាប់ ឬក៏ក្រុមហ៊ុនគណនេយ្យ។ ក្នុងជំហានទីបួន សហគ្រាសចាំបាច់ត្រូវទូទាត់ប្រាក់សម្រាប់តែម និងថ្លៃចុះបញ្ជី។ ចាប់ពីជំហានទីប្រាំ ដល់ជំហានទីប្រាំបី សហគ្រាសចាំបាច់ត្រូវដាក់ឯកសារតាមការតម្រូវជាច្រើន រួមមានដូចជាលេខគណនីធនាគារ និងវិញ្ញាបនបត្របញ្ជាក់ការទូទាត់ប្រាក់ជូនដល់ DICA ដើម្បីបានទទួលវិញ្ញាបនបត្រ បញ្ជាក់ការចុះបញ្ជីក្រុមហ៊ុន។ ក្នុងជំហានទីប្រាំបួន ដែលជំហានទីដប់មួយ អាជីវកម្មចាំបាច់ត្រូវឆ្លងកាត់ ការចុះបញ្ជីជាមួយនាយកដ្ឋានពន្ធដារ។ ជំហានចុងក្រោយគឺការចុះបញ្ជីសហគ្រាសជាមួយមូលនិធិសន្តិសុខសង្គម។

### តារាងទី ៤ ៖ ជំហានដើម្បីចុះបញ្ជីអាជីវកម្មក្នុងប្រទេសមីយ៉ាន់ម៉ា

| ជំហាន | ដំណើរការ | ស្ថាប័ន/ ទីភ្នាក់ងារ | ឯកសារដែលត្រូវទទួលបាន | រយៈពេល និង ថ្លៃសេវា |
|---|---|---|---|---|
| **ជំហានទី ១** | ធ្វើការត្រួតពិនិត្យឈ្មោះក្រុមហ៊ុន(កិច្ចការនេះអាចធ្វើឡើងតាមអនឡាញ ឬទៅកាន់ DICA) | ការិយាល័យចុះបញ្ជីក្រុមហ៊ុន (CRO) នៅអគ្គនាយកដ្ឋានវិនិយោគ និងរដ្ឋបាលក្រុមហ៊ុន (DICA) | អនុម័តលើឈ្មោះក្រុមហ៊ុន | ១ ថ្ងៃ<br>ថ្លៃសេវា៖ ១០០០ ក្យាត (០,៦០ ដុល្លារ) |
| **ជំហានទី ២** | ស្នើសុំវិញ្ញាបនបត្របង្កើតក្រុមហ៊ុន | អគ្គនាយកដ្ឋានវិនិយោគ និងរដ្ឋបាលក្រុមហ៊ុន (DICA) | ឯកសារដាក់ពាក្យសម្រាប់ការបង្កើតក្រុមហ៊ុន | ១ ថ្ងៃ<br>ថ្លៃសេវា៖ ៥ ១០០ ក្យាត (៣,៣៦ ដុល្លារ) |
| **ជំហានទី ៣** | ទទួលបានហត្ថលេខាពីនាយកនៅចំពោះមុខមេធាវីដែលមានការបញ្ជាក់ជាសាធារណៈ | ក្រុមហ៊ុនច្បាប់ ឬគណនេយ្យ | | ១ ថ្ងៃ<br>ថ្លៃសេវា៖ ៤០ ០០០ ក្យាត (២៦,៣៤ ដុល្លារ) |
| **ជំហានទី ៤** | បង់ប្រាក់ថ្លៃតែម និងថ្លៃសេវាចុះបញ្ជី | អគ្គនាយកដ្ឋានវិនិយោគ និងរដ្ឋបាលក្រុមហ៊ុន (DICA) | លិខិតដើម្បីបញ្ជាក់ថាក្រុមហ៊ុនបានចុះបញ្ជីរួចហើយ | ១ ថ្ងៃ |
| **ជំហានទី ៥** | បើកគណនីធនាគារ | ធនាគារ | ភស្តុតាងបញ្ជាក់គណនីធនាគារ | ១ ថ្ងៃ<br>មិនគិតសេវា |

| ជំហាន | ដំណើរការ | ស្ថាប័ន/ ទីភ្នាក់ងារ | ឯកសារដែល ត្រូវទទួលបាន | រយៈពេល និង ថ្លៃសេវា |
| --- | --- | --- | --- | --- |
| ជំហានទី ៦ | ទទួលបានវិញ្ញាបនបត្របញ្ជាក់ការបង្កើត | អគ្គនាយកដ្ឋានវិនិយោគ និងរដ្ឋបាលក្រុមហ៊ុន (DICA) | វិញ្ញាបនបត្របញ្ជាក់ការបង្កើតក្រុមហ៊ុន | ៣ ថ្ងៃ<br>បង់ប្រាក់ជាផ្នែកមួយនៃថ្លៃបង្កើតក្រុមហ៊ុន |
| ជំហានទី ៧ | ដាក់ឯកសារវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជី (CRD)<br><br>ដាក់ទម្រង់លេខ ៦បញ្ជីឈ្មោះអ្នកកាន់ភាគហ៊ុន)<br>និងទម្រង់លេខ ២៦ (បញ្ជីឈ្មោះនាយក) | អគ្គនាយកដ្ឋានវិនិយោគ និងរដ្ឋបាលក្រុមហ៊ុន (DICA) | | ១ ថ្ងៃ<br>ថ្លៃសេវា៖ ៥០០០០ ក្បាត (៣៣ ដុល្លារ) |
| ជំហានទី ៨ | ទទួលបានត្រា ឬ ត្រាកៅស៊ូ | អ្នកធ្វើត្រា | ត្រាក្រុមហ៊ុន ឬត្រាកៅស៊ូ | ១ ថ្ងៃ<br>ថ្លៃសេវា៖ ២០០០ ក្បាត (១,៣២ ដុល្លារ) |
| ជំហានទី ៩ | ចុះបញ្ជីជាមួយការិយាល័យពន្ធ | ការិយាល័យពន្ធ | | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ជំហានទី ១០ | ចុះបញ្ជីពន្ធពាណិជ្ជកម្ម (ប្រហាក់ប្រហែលនឹង VAT) | ការិយាល័យនាយកដ្ឋានចំណូលផ្ទៃក្នុងរបស់ក្រុង | | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ជំហានទី ១១ | ការចុះបញ្ជីនិយោជិតនៅការិយាល័យការងារក្នុងក្រុង<br><br>(ការចុះបញ្ជីនេះគឺត្រូវធ្វើជាកាតព្វកិច្ចសម្រាប់គោលបំណងនៃពន្ធ) | ការិយាល័យការងាររបស់ក្រុង | | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ជំហានទី ១២ | ចុះបញ្ជីជាមួយក្រុមប្រឹក្សាភិបាលសន្តិសុខសង្គមសម្រាប់អត្ថប្រយោជន៍សន្តិសុខសង្គម | ក្រុមប្រឹក្សាសន្តិសុខសង្គម | | ១ ថ្ងៃ<br>ឥតគិតថ្លៃ |
| ជំហានទី ១៣ | ចាប់ផ្តើមអាជីវកម្ម | | | |

## IV. សន្និដ្ឋាន និងអនុសាសន៍

មេរៀនបានទទួលពីបណ្តាលប្រទេសអាស៊ាន ជាពិសេសករណីសិក្សាពីប្រទេសសិង្ហបុរី ស្នើឲ្យឃើញថា ការបង្កើតឲ្យមានវេទិកាសំចតតែមួយកន្លែងតាមអនឡាញ អាចជាវិធីមានប្រសិទ្ធផលខ្ពស់បំផុត ដើម្បីកាត់បន្ថយពេលវេលា និងការចំណាយសម្រាប់ការចុះបញ្ជីអាជីវកម្ម ហើយក៏អាចមានសារៈប្រយោជន៍សម្រាប់ការ ស្ថាបនាភាពស៊ីសង្វាក់ និងបរិស្ថានគោលនយោបាយ ស៊ីសង្វាក់ និងមានតម្លាភាព សម្រាប់ការលូតលាស់របស់ MSME។ ការចុះបញ្ជីអាជីវកម្ម ជៀសមិនផុតគឺត្រូវទាមទារឲ្យមានអន្តរទំនាក់ទំនងជាច្រើន ជាមួយស្ថាប័ននានារបស់រដ្ឋ មូលហេតុដែលនាំឲ្យមានទិដ្ឋភាពផ្សេងៗនៃប្រតិបត្តិការអាជីវកម្ម ពាក់ព័ន្ធជាមួយអាជ្ញាធរ នៅក្នុងស្ថាប័ននិយ័តកម្មខុសៗគ្នារបស់រដ្ឋាភិបាល។ ដើម្បីសម្របសម្រួលលើនិយ័តកម្មផ្សេងៗ ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពមួយ គឺត្រូវបង្កើតវេទិកាសំចតតែមួយកន្លែងតាមអនឡាញ ដែលអាចដាក់បញ្ចូលការតម្រូវទាំងអស់ ដែលគ្រប់គ្រងដោយស្ថាប័ននិយ័តកម្ម ផ្សេងៗរបស់រដ្ឋាភិបាល។ ចាំបាច់ត្រូវកត់សម្គាល់ថា គោលវិធីបែបចម្រុះនេះ មិនអាចកាត់បន្ថយតួនាទី របស់និយ័តកររដ្ឋាភិបាល ពាក់ព័ន្ធនោះឡើយ។ ជំនួសមកវិញការធ្វើបែបនេះអាចជួយបង្កើតគណនេយ្យភាព ប្រសិទ្ធផល និងតម្លាភាពនៃការគាំទ្ររបស់រដ្ឋាភិបាល ចំពោះការចុះបញ្ជីអាជីវកម្ម។

ទោះយ៉ាងណាក្តី វេទិកាសំចតតែមួយកន្លែងតាមអនឡាញ ដែលបំពេញមុខងារបានត្រឹមត្រូវ សម្រាប់ការចុះបញ្ជីអាជីវកម្មគឺទាមទារឲ្យគ្រប់សហគ្រាសទាំងអស់ ត្រូវទទួលបានអត្តសញ្ញាណក្រុមហ៊ុន ( ID សហគ្រាស ) ដែលមានតែមួយគត់មិនជាន់គ្នា ពោលគឺត្រូវដំណើរការក្នុងលក្ខណៈដូចគ្នាជាមួយទិដ្ឋភាពដែលពលរដ្ឋម្នាក់ៗបានទទួលលេខអត្តសញ្ញាណពិសេសមានតែមួយគត់នោះផងដែរ។ លេខសម្គាល់អត្តសញ្ញាណសហគ្រាសមានតែមួយគត់មិនជាន់គ្នានេះ អនុញ្ញាតឲ្យក្រុមហ៊ុនអាចមានលទ្ធភាព ចូលទៅកាន់វេទិកាចុះបញ្ជីតាមអនឡាញក៏ដូចជា ទាញប្រយោជន៍បានច្រើនបំផុតពីវេទិកានេះ ព្រមទាំងសេវារបស់វេទិកានេះ ហើយក្នុងនោះក៏រួមមានដូចជា ការរក្សាឈ្មោះក្រុមហ៊ុន ការបើកគណនីធនាគារ ការទទួលបានការអនុញ្ញាត និងការចុះបញ្ជីជាមួយអាជ្ញាធរពន្ធជាដើម។

លើសពីនេះ នៅពេលដែលលេខអត្តសញ្ញាណពិសេសមានតែមួយគត់បានបង្កើតឡើងសម្រាប់សហគ្រាស មួយហើយជាការសំខាន់ដែលលេខអត្តសញ្ញាណនោះ ត្រូវបានទទួលស្គាល់ផ្ទះនៅក្នុងវេទិកាសំចតតែមួយកន្លែងតាមអនឡាញ ក៏ដូចជាវេទិកាស្របគ្នាដ៏ទៃទៀតដែលប្រតិបត្តិការដោយនាយកដ្ឋានផ្សេងៗរបស់រដ្ឋាភិបាល។ ការណែនាំច្បាស់លាស់ស្តីពីថ្លៃសេវា និងពេលវេលាដែលត្រូវការសម្រាប់អនុម័ត ចាំបាច់ត្រូវបង្ហាញនៅលើវេទិកាតាមអនឡាញនេះ។ ប្រព័ន្ធអនឡាញក៏គួរតែអនុញ្ញាតឲ្យមានការអនុម័តជាស្វ័យប្រវត្តិ ក្នុងករណីទីភ្នាក់ងារទទួលខុសត្រូវ មិនអាចឆ្លើយតបចំពោះសំណើក្នុងអំឡុងរយៈពេលដែលបានកំណត់។

ដើម្បីផ្តល់សេវាចុះបញ្ជីអាជីវកម្ម សំចតតែមួយកន្លែងនៅក្នុងលក្ខណៈបែបឌីជីថលនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI) ប្រទេសកម្ពុជាគួរពិចារណាចម្លងការអនុវត្តល្អនៃគេហទំព័រអាជ្ញាប័ណ្ណតែមួយរបស់ប្រទេសសិង្ហបុរីដែលអាចជាគំរូដើម្បីកាត់បន្ថយភាពមិនច្បាស់លាស់ ពេលវេលានិងការចំណាយ ដើម្បីចុះបញ្ជីអាជីវកម្ម ក៏ដូចជាដើម្បីលើកកម្ពស់ភាពអនុលោមតាមកាតព្វកិច្ចពន្ធផងដែរ។ ម្យ៉ាងវិញទៀតសេវាតាមឌីជីថលរបស់វេទិកាអនឡាញ ក៏អាចជួយឲ្យសហគ្រិន MSME យល់កាន់តែប្រសើរអំពីវិធាន និងនីតិវិធី សម្រាប់ការចុះបញ្ជីអាជីវកម្មផងដែរ។ ដោយអនុវត្តតាមគោលវិធីមួយជំហានម្តងៗ វេទិកាតាមអនឡាញអាចត្រូវបានច្របាច់បញ្ចូល ជាមួយមុខងារកាន់តែច្រើនថែមទៀត ដែលផ្តល់ព័ត៌មានលម្អិតស្តីពីនីតិវិធី ឯកសារ និងថ្លៃសេវាការតម្រូវសម្រាប់ការចុះបញ្ជីអាជីវកម្ម។ បន្ថែមលើនេះ ជាការល្អប្រសិនបើ MISTI ក៏អាចពិចារណាផ្តល់កម្មវិធីកសាងសមត្ថភាព ទាំងតាមឡាញ និងតាមជាក់ស្តែងក្រៅប្រព័ន្ធអនឡាញ ជូនដល់សហគ្រិន MSME ដើម្បីជាមគ្គុទេសក៍ ក្នុងការចុះបញ្ជីអាជីវកម្ម ដោយរៀបរាប់លម្អិតអំពីឯកសារ និងជំហានដែលត្រូវការ។

ការរៀបចំការប្រព័ន្ធចុះអនឡាញដែលស្ថិតនៅក្រោមអាស័យដ្ឋាននៃគេហទំព័ររបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ទិន្នន័យព័ត៌មានសម្ងាត់របស់ MSME ដែលរក្សាទុកនៅក្នុងសើវើរ ចាំបាច់ត្រូវចែករំលែកជាមួយច្រកគេហទំព័រដទៃទៀតដែលស្ថាប័ននានារបស់រដ្ឋាភិបាលពាក់ព័ន្ធជាមួយការចុះបញ្ជី MSME ផងដែរ។ ដោយឡែកច្រកគេហទំព័រទាំងនេះរួមមានដូចជា ច្រកគេហទំព័រការចុះបញ្ជីអាជីវកម្មតាមអនឡាញ ដែលដាក់ឲ្យប្រើប្រាស់ដោយក្រសួងពាណិជ្ជកម្ម នៅឆ្នាំ ២០១៥ និងវេទិកាការចុះបញ្ជីពន្ធតាមអនឡាញ ដែលដាក់ឲ្យប្រើប្រាស់ដោយអគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ ២០១៤។ នៅពេលក្រោយមក វេទិកានេះនឹងអាចបង្កើតអត្ថប្រយោជន៍ជាច្រើនប្រសិនបើវេទិកានេះអាច ត្រូវបានធ្វើសមាហរណកម្ម ផ្តល់ច្រកផ្លូវតាមអនឡាញសំចតតែមួយកន្លែង សម្រាប់ការចុះបញ្ជីអាជីវកម្មក្នុងប្រទេសកម្ពុជា។ វេទិកានេះក៏គួរតែអាចគាំទ្រឲ្យប្រទេសកម្ពុជាស្ថិតក្នុងជំហរកាន់តែប្រសើរក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថលដើម្បីឈានទៅសំរេចចក្ខុវិស័យឧស្សាហកម្ម ៤.០។

# គន្ថនិទ្ទេស


**ACRA. (2018).** Annual Report 2017/2018: Promoting a Trusted and Vibrant Business Environment in Singapore. https://www.acra.gov.sg/training-and-resources/publications/reports/acra-annual-reports.

**ASEAN. (2016).** ASEAN Work Programme on Starting a Business. Jakarta: ASEAN Secretariat.

**ASEAN. (2017).** ASEAN Regional Principles for Good Business Registration Practices. https://asean.org/storage/2017/09/ANNEX-12-ASEAN-Regional-Principles-for-Good-Business-Regn-Practices_final-14-Aug.pdf.

Berkel, H., M. Cardona, H. Hansen, J. Rand, P.Castro Rodriguez, N. Trifković, E. de Witte, H. Zille, K.Swe Latt and F. Tarp. (2018). Myanmar Micro, Small, And Medium Enterprise Survey 2017: Descriptive Report. Helsinki: UNU-WIDER, University of Copenhagen, Central Statistical Organization.

**Dayan, Z. and W. Bolislis. (2017). Business registration pillars:** Good regulatory practice for ASEAN. Paris: OECD Regulatory Policy Working Papers, No. 9, OECD Publishing.

**Giorgi, G.De and Rahman,A . (2013).** SME's registration: Evidence from an RCT In Bangladesh. Economics letters.

**Government of Myanmar. (2018).** The Myanmar Companies Regulations 2018,. Notification No. 66/ 2018. www.myco.dica.gov.mm/documentation/mm/MCL.Regulations.English.pdf.

**Government of Singapore. (2017).** LicenceOne. www.licence1.business.gov.sg/web/frontier/home.

**ITC. (2018).** SME Competitiveness Outlook 2018: Business Ecosystems for the Digital Age. ITC.

**Mel, S.De, Mckenzie.D and Woodruff.C. (2013).** The Demand for, and Consequences of, Formalization among Informal Firms in Sri lanka. American Economic Association.

**OECD/ERIA. (2018).** SME Policy Index: ASEAN 2018: Boosting Competitiveness and Inclusive Growth. OECD Paris/ Economic Research Institute for ASEAN and East Asia, Jakarta. https://doi.org/10.1787/9789264305328-en.

**Rand John and Torm Nina. (2012).** The benifit of formalization: Evidence from Vietnames Manufacturing SMEs. World Development Vol.40, No.5.

**MSME Corp. Malaysia. (2017).** MSME Annual Report 2016/17. www.MSMEcorp.gov.my/index.php/en/MSME-annual-report-2015-16?id=2150.

**World Bank . (2019b). Doing Business 2019:** Singapore . World Bank Group.

**World Bank. (2019a).** Doing Business. http://www.doingbusiness.org/en/data/exploretopics/starting-a-business/good-practices.



Photo credit: ADB Photo | Chor Sokunthea

DESA Department of Economic and Social Affairs